

ទីលានស្ទឹងមានជ័យមុនគំរោងសាកល្បង (ខែកញ្ញា ២០០៣)



ទីលានស្ទឹងមានជ័យគំរោងសាកល្បង (ខែមិនា ២០០៤)

Plate 1: ការកែលំអរទីលានចាក់សំរាមស្ទឹងមានជ័យ





**ការចាក់សំណល់**

ក្នុងតំបន់ពាណិជ្ជកម្ម

**ការចាក់សំណល់**

ក្នុងតំបន់គេហដ្ឋានធម្មតា





**ការប្រមូលសំណល់**

ការប្រមូលសំណល់ដោយក្រុមជួយខ្លួនឯង

**ការប្រមូលសំណល់**

ការប្រមូលសំណល់ដោយក្រុមហ៊ុនឯកជន





**ការកែច្នៃ**

អ្នកទិញសំណល់កែច្នៃ (អេតចាយ)

**ការកែច្នៃ**

ការទុកដាក់សំណល់កែច្នៃនៅផ្ទះ

Plate 2: ស្ថានភាពបច្ចុប្បន្ន នការគ្រប់គ្រងសំណល់រឹងនាទីក្រុងភ្នំពេញ





**ការកែច្នៃ**

ហាងកែច្នៃ

**ការកែច្នៃ**

សំណល់សំភារៈសំណង់





**ទីលានចុងក្រោយ**

ទីលានចាក់សំរាមស្ទឹងមានជ័យ

**ទីលានចុងក្រោយ**

ទីលានចាក់សំរាមស្ទឹងមានជ័យ





**ទីលានចុងក្រោយ**

ទីលានចាក់សំរាមស្ទឹងមានជ័យ

**ការញែកសំណល់**

ទីលានចាក់សំរាមស្ទឹងមានជ័យ

Plate 3: ស្ថានភាពបច្ចុប្បន្ន នការគ្រប់គ្រងសំណល់រឹងនាទីក្រុងភ្នំពេញ



**សកម្មភាព NGO: PSE**
កម្មវិធីអប់រំក្រៅប្រព័ន្ធសំរាប់កុមាររើសសំរាម



**សកម្មភាព NGO: VCAO**
សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ



**សកម្មភាព NGO: World Vision Cambodia**
កម្មវិធីអប់រំក្រៅប្រព័ន្ធសំរាប់កុមាររើសសំរាម



**សកម្មភាព NGO: CSARO**
ការផលិតជីកំប៉ុស



ការចាក់សំណល់ខុសច្បាប់



ការចាក់សំណល់ខុសច្បាប់

Plate 4: ស្ថានភាពបច្ចុប្បន្ន នការគ្រប់គ្រងសំណល់រឹងនាទីក្រុងភ្នំពេញ



**WACS:**
ការប្រមូលសំណល់ពីគេហដ្ឋាន



**WACS:**
ការថ្លឹងសំណល់ប្រមូលពីសំណល់ពីគេហដ្ឋាន



**WACS:**
ការបែងចែកសំណល់ដើម្បីផលិតជីកំប៉ុស



**WACS:**
ការបែងចែកសំណល់ដើម្បីផលិតជីកំប៉ុស



**POS**
ការធ្វើសំភាសន៍ស្ទង់មតិ



**POS**
ការធ្វើសំភាសន៍ស្ទង់មតិ

Plate 5: ការសិក្សា



SES
ការប្រជុំក្រុមគោលដៅ(អ្នករើសសំរាម)



SES
ការប្រជុំបន្ថែម (អ្នករើសសំរាម)



ការសិក្សាលើសហគ្រាស



ការសិក្សាលើវិទ្យាស្ថានវេជ្ជសាស្ត្រ



ការសិក្សាលើសហគ្រាស



ការសិក្សាលើវិទ្យាស្ថានវេជ្ជសាស្ត្រ

Plate 6: ការសិក្សា



ការសិក្សាលើការកែច្នៃ

សហគ្រាសកែច្នៃក្រដាស



ការសិក្សាលើការកែច្នៃ

សហគ្រាសកែច្នៃដែក



ការសិក្សាលើការកែច្នៃ

សំណល់ដែកសំរាប់កែច្នៃនៅរោងជាងសិប្បកម្ម



ការសិក្សាលើការកែច្នៃ

សហគ្រាសកែច្នៃជ័រ



ការសិក្សាភូមិសាស្ត្រទីលានស្ទឹងមានជ័យ



ការសិក្សាលើគុណភាពទឹក

Plate 7: ការសិក្សា





អាងចំរោះទឹកសំអុយ(កំពុងសាងសង់)

ការសាងសង់ផ្លូវធំក្នុងទីលាន





ការសាងសង់ប្លុកគំរូ

ការសាងសង់ទំនប់ការពារ





ប្លុកគំរូ និងបំពង់យកឧស្ម័ន

ការប្រើប្រាស់ឧស្ម័ន(សំរាប់ផលិតធ្យូង)
**CDM Project by Japan's MOE**

Plate 8: គំរោងសាកល្បង

ការកែលំអរទីលានចាក់សំរាមស្ទឹងមានជ័យ (1)



ការប្រជុំសហគមន៍
ពីបទបញ្ហារើសសំរាម



ការចុះបញ្ជីអ្នករើសសំរាម
នៅទីលានស្ទឹងមានជ័យ



ការសាងសង់កន្លែងចាក់សំរាម



ការបែងចែកតំបន់ការងារ(តំបន់រើសសំរាម)



ការបែកចែកតំបន់ការងារ
(តំបន់ចាក់សំរាម)



ការប្រជុំក្រុមការងារ
(JICA team, PPWM, VCAO, Police, Waste Picker Assistants)

Plate 9: គំរោងសាកល្បង

ការកែលំអរទីលានចាក់សំរាមស្ទឹងមានជយ (2)



ការប្រជុំសហគមន៍



ការកែលំអរផ្លូវដោយចូលរួមពីសហគមន៍




ការបង្ហាញពីរថយន្តដឹកសំរាម



ធុងសំរាមតាមផ្លូវ



ការប្រមូលសំរាមដោយក្រុមជួយខ្លួនឯង



យុទ្ធនាការអប់រំសាធារណៈនៅជ្រោយចង្វារ

Plate 10: គំរោងសាកល្បង

ការកែលំអរប្រពន្ធប្រមូលសំណល់



សង្កាត់មនោរម្យមុនគំរោងសាកល្បង



ការសិក្សាជាមូលដ្ឋាននៅសង្កាត់មនោរម្យ



ការប្រជុំសហគមន៍នៅបឹងត្របែក



យុទ្ធនាការបោសសំអាត

គំរោងសាកល្បង២ ការអប់រំសាធារណ២



ការសាងសង់ជញ្ជីងថ្លឹង



បណ្តុះបណ្តាលលើការប្រើប្រាស់កុំព្យូទ័រ

Plate 11: គំរោងសាកល្បង

ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងទិន្នន័យលើការគ្រប់គ្រងសំណល់រឹង



ការសិក្សាទីផ្សារជីកំប៉ុស្ត



ការសិក្សាទីផ្សារជីកំប៉ុស្ត



ការសិក្សានៅទីលានកសិដ្ឋាន



ការសិក្សានៅទីលានកសិដ្ឋាន



ការសិក្សានៅទីលានកសិដ្ឋាន



ការផលិតជីកំប៉ុស្តនៅទីលានស្ទឹងមានជ័យ

Plate 12: គំរោងសាកល្បង

ការអភិវឌ្ឍន៍និងជំរុញទីផ្សារជីកំប៉ុស្តសំណល់ទីក្រុង





ការសិក្សាលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ការសិក្សាលើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន





ការជួបជុំជាសាធារណៈលើកទីមួយ ការជួបជុំជាសាធារណៈលើកទីមួយ





ការជួបជុំជាសាធារណៈលើកទីពីរ ការជួបជុំជាសាធារណៈលើកទីពីរ

Plate 13: ការសិក្សាអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
លើគំរោងអភិវឌ្ឍន៍ទីលានដង្កោ



ការបណ្តុះបណ្តាលសមភាគីនៅឡាវ




ការបណ្តុះបណ្តាលសមភាគីនៅឡាវ
(ទស្សនកិច្ចសិក្សា)



ការបណ្តុះបណ្តាលសមភាគីនៅសាលាក្រុងភ្នំពេញ



ការបណ្តុះបណ្តាលសមភាគីនៅសាលាក្រុងភ្នំពេញ
(ទស្សនកិច្ចសិក្សានៅទីលានស្ទឹងមានជ័យ)




សិក្ខាសាលាពីការផ្ទេរបច្ចេកវិទ្យា



សិក្ខាសាលាពី **3R**
(ទស្សនកិច្ចសិក្សាហាងកែច្នៃនៅស្ទឹងមានជ័យ)

Plate 14: ការកសាងសមត្ថភាព

# មាតិកា


**អារម្ភកថា**

**លិខិតផ្ទេរ**

**ចំនុចសំខាន់ៗនៃផែនការមេ**

**ផែនទីស្តីពីតំបន់សិក្សា** .......... i

**រូបភាព** .......... ii

**មាតិកា** .......... xvii

**បញ្ជីតារាង** .......... xxi

**បញ្ជីរូបភាព** .......... xxiii

**បញ្ជីអក្សរកាត់** .......... xxiv

1 គំរោងការសិក្សា .......... 1-1

1.1 ប្រវត្តិ .......... 1-1

1.2 គំរោងសិក្សា .......... 1-2

1.3 គោលបំណង និងតំបន់សិក្សា .......... 1-3

1.3.1 គោលបំណង .......... 1-3

1.3.2 តំបន់សិក្សា .......... 1-3

1.3.3 សំណល់ដែលមានក្នុងតំបន់សិក្សា .......... 1-4

1.4 គោលនយោបាយគ្រឹះនៃការសិក្សា .......... 1-4

1.5 ពេលវេលានៃការសិក្សា .......... 1-5

1.6 ការរៀបចំការសិក្សា .......... 1-5

1.6.1 សមាជិកក្រុមសិក្សា .......... 1-5

1.6.2 សមាជិកជាបុគ្គលិកសមភាគី .......... 1-6

1.7 ការផ្ទេរបច្ចេកវិទ្យា .......... 1-6

1.8 របាយការណ៍ .......... 1-6

1.9 ឯកសារបន្ទុករបស់ *JICA* លើការពិចារណាលើបរិស្ថាន និងសង្គម .......... 1-8

2 ស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន 2-1

2.1 ស្ថានភាពនៅតំបន់សិក្សាបច្ចុប្បន្ន 2-1
2.1.1 បរិស្ថានធម្មជាតិ 2-1
2.1.2 ចំនួនប្រជាជន 2-1
2.1.3 រចនាសម្ព័ន្ធទីប្រជុំជន 2-2
2.1.4 ស្ថានភាពសេដ្ឋកិច្ច 2-3

2.2 មូលដ្ឋានស្រាវជ្រាវ 2-3
2.2.1 ការបង្កើតសំណល់ និងបរិមាណចាក់ 2-4
2.2.2 សមាសភាពសំណល់ 2-4
2.2.3 សំណល់វេជ្ជសាស្ត្រ និងសំណល់ឧស្សាហកម្ម 2-5
2.2.4 លំហូរសំណល់ 2-6

2.3 ការវាយតម្លៃការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន 2-8
2.3.1 សង្ខេបប្រព័ន្ធគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន 2-8
2.3.2 ការវាយតម្លៃលើការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន 2-12
2.3.3 បញ្ហាបច្ចុប្បន្នពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង 2-21

3 ផែនការមេគ្រប់គ្រងសំណល់រឹង 3-1

3.1 ផែនការមេ 3-1
3.1.1 គោលបំណង 3-1
3.1.2 ឆ្នាំគោលដៅ 3-1

3.2 គ្របខ័ណ្ឌការងារសំរាប់ធ្វើផែនការមេ 3-2
3.2.1 ការព្យាករណ៍ចំនួនប្រជាជន 3-2
3.2.2 គ្របខ័ណ្ឌសេដ្ឋកិច្ច 3-3
3.2.3 ព្យាករណ៍បរិមាណ និងសមាសភាពសំណល់នាពេលអនាគត 3-3
3.2.4 ព្យាករណ៍សំណល់ឧស្សាហកម្ម និងវេជ្ជសាស្ត្រ 3-5

3.3 ការជ្រើសរើសប្រព័ន្ធបច្ចេកទេសប្រសើរបំផុត 3-6

3.4 បញ្ហាស្ថាប័ន 3-7
3.4.1 ប្រព័ន្ធច្បាប់ 3-7
3.4.2 រដ្ឋបាល និងការរៀបចំ 3-9
3.4.3 ដៃគូសាធារណៈ និងឯកជន 3-10
3.4.4 ការកសាងសមត្ថភាព 3-12

3.5 តួលេខគោលដៅ និងយុទ្ធសាស្ត្ររបស់ផែនការមេ 3-12
3.5.1 តួលេខគោលដៅ 3-12
3.5.2 យុទ្ធសាស្ត្រដើម្បីសំរេចគោលដៅ 3-13

3.5.3 លំហូរសំណល់នាពេលអនាគត........................................3-24

3.5.4 ផែនការមេគ្រប់គ្រងសំណល់រឹង........................................3-27

3.5.5 គំរោងអាទិភាព........................................3-31

3.5.6 ប្លង់ទីតាំងសំរាប់ហេដ្ឋារចនាសម្ព័ន្ធនាពេលអនាគត........................................3-32

3.5.7 កម្មវិធីអនុវត្ត........................................3-34

3.5.8 ថ្លៃដើមគំរោង........................................3-35

3.5.9 ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុរបស់ផែនការមេ........................................3-35

# 4 គំរោងសាកល្បង........................................4-1

## 4.1 ការជ្រើសរើសគំរោងសាកល្បង........................................4-1

## 4.2 ការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ........................................4-1

4.2.1 ខ្លឹមសាសំខាន់ៗ នៃការកែលំអ........................................4-1

4.2.2 លទ្ធផលការសិក្សា........................................4-5

4.2.3 បញ្ហាច្រកចូលទីតាំងចាក់ និងបញ្ហានានា........................................4-9

4.2.4 កិច្ចការដែលត្រូវធ្វើដោយសាលាក្រុង និងរដ្ឋាករ........................................4-10

## 4.3 ការកែលំអប្រព័ន្ធប្រមូលសំរាម........................................4-12

4.3.1 ការណែនាំប្រព័ន្ធប្រមូលដោយធុងសំរាមធំ........................................4-12

4.3.2 ការពង្រីកសេវាកម្មប្រមូលសំរាម........................................4-16

## 4.4 ការអប់រំជាសារធារណ........................................4-22

4.4.1 ផែនការគំរោង........................................4-22

4.4.2 គំហើញនៃការសិក្សា........................................4-23

## 4.5 ការអភិវឌ្ឍន៏ និងការបង្កើនទីផ្សារជីកំប៉ុស្ត........................................4-24

4.5.1 ចំណុចសំខាន់ៗនៃការសិក្សា........................................4-24

4.5.2 លទ្ធផលនៃការសិក្សា........................................4-25

## 4.6 ការអភិវឌ្ឍន៏ការគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ រ.គ.ស.ត........................................4-25

4.6.1 ចំនុចសំខាន់ៗនៃការអភិវឌ្ឍន៏........................................4-25

4.6.2 លទ្ធផលការសិក្សា........................................4-26

# 5 ការកសាងសមត្ថភាព........................................5-1

## 5.1 គោលបំណងនិងវិធីសាស្ត្រ........................................5-1

5.1.1 គោលបំណង........................................5-1

5.1.2 វិធីសាស្ត្រ........................................5-1

5.2 កសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈការអនុវត្តន៍គំរោងសាកល្បង.......5-1
5.2.1 ការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ.......5-1
5.2.2 ការកែលំអប្រព័ន្ធប្រមូលសំរាម.......5-3
5.2.3 យុទ្ធនាការអប់រំសាធារណៈ.......5-5
5.2.4 ការបង្កើតប្រព័ន្ធត្រួតពិនិត្យជាប្រចាំ (ក្រោមគំរោងសាកល្បងនៃការកែលំអទីលានស្ទឹងមានជ័យ.......5-7

5.3 ការកសាងសមត្ថភាពតាមរយៈធ្វើសិក្ខាសាលា ជាដើម.......5-7

6 ការសិក្សាពីលទ្ធភាពនៃគំរោង.......5-1

6.1 ការជ្រើសរើសគំរោងអាទិភាព.......6-1

6.2 ផែនការអភិវឌ្ឍន៏ទីលានចាក់សំរាមដង្កោ.......6-1
6.2.1 គោលគំនិតរៀបចំ.......6-1
6.2.2 បរិស្ថានធម្មជាតិនៃទីតាំងគំរោងនៅដង្កោ.......6-1
6.2.3 ការរៀបចំចំណុចសំខាន់ៗ.......6-2
6.2.4 ការវាយតំលៃគំរោង.......6-8

6.3 គំរោងពង្រីកសេវាកម្មប្រមូលសំរាម.......6-17
6.3.1 គោលគំនិតរៀបចំ.......6-17
6.3.2 ការរៀបចំចំណុចសំខាន់ៗ.......6-18
6.3.3 ការវាយតំលៃគំរោង.......6-23

6.4 គំរោងបិទទីលានស្ទឹងមានជ័យ.......6-28
6.4.1 គោលគំនិតក្នុងការរៀបចំ.......6-28
6.4.2 ការរៀបចំចំណុចសំខាន់ៗ.......6-28
6.4.3 ការវាយតំលៃគំរោង.......6-31

7 ការសន្និដ្ឋាន និងការផ្តល់អនុសាសន៏.......7-1

7.1 ការសន្និដ្ឋាន.......7-1
7.1.1 បញ្ហាផ្សេងៗលើការគ្រប់គ្រងសំណល់រឹងនាទីក្រុងភ្នំពេញនាពេលបច្ចុប្បន្ន.......7-1
7.1.2 ផែនការមេ.......7-2
7.1.3 គំរោងអទិភាព.......7-5
7.1.4 បញ្ហានៃការគ្រប់គ្រងកាកសំណល់រឹងដ៏ទៃទៀត និងវិធានការណែនាំ.......7-8

7.2 អនុសាសន៏.......7-9

7.2.1 អនុសាសន៍សំរាប់ការកែលំអរផែនការមេ.......7-9

# បញ្ជីតារាង

Page:

Table 2-1: ចំនួនប្រជាជន ដង់ស៊ីតេប្រជាជន និងចំនួនផ្ទះ ក្នុងឆ្នាំ ២០០៣ ........ 2-2
Table 2-2: អាត្រាបង្កើតសំណល់ និងបរិមាណចាក់ ក្នុងឆ្នាំ ២០០៣ ........ 2-4
Table 2-3: ការប្រៀបធៀបសមាសភាពសំណល់ដែលចាក់ពីផ្ទះ ........ 2-4
Table 2-4: បរិមាណសំណល់វេជ្ជសាស្ត្រ បង្កើតក្នុងឆ្នាំ ២០០៣ ........ 2-5
Table 2-5: បរិមាណសំណល់ឧស្សាហកម្ម បង្កើតក្នុងឆ្នាំ ២០០៣ ........ 2-6
Table 2-6: ប្រព័ន្ធបច្ចេកទេសបច្ចុប្បន្នក្នុងឆ្នាំ ២០០៣ ........ 2-8
Table 2-7: ប្រព័ន្ធស្ថាប័នបច្ចុប្បន្ន ........ 2-11
Table 2-8: ការវាយតម្លៃស្ថានភាពគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញបច្ចុប្បន្ន ........ 2-12
Table 3-1: ព្យាករណ៍ចំនួនប្រជាជន ........ 3-2
Table 3-2: សន្ទស្សន៍សេដ្ឋកិច្ចក្នុងតំបន់សិក្សា ........ 3-3
Table 3-3: ព្យាករណ៍អាត្រានៃការបង្កើតសំណល់ ........ 3-4
Table 3-4: ព្យាករណ៍ចំនួនប្រភពចាក់សំណល ........ 3-4
Table 3-5: ព្យាករណ៍បរិមាណបង្កើតសំណល់ ........ 3-4
Table 3-6: ព្យាករណ៍សមាសភាពសំណល់ ........ 3-5
Table 3-7: ព្យាករណ៍នៃការបង្កើតសំណល់វេជ្ជសាស្ត្រ ........ 3-5
Table 3-8: ព្យាករណ៍នៃការបង្កើតសំណល់ឧស្សាហកម្ម ........ 3-6
Table 3-9: ការជ្រើសរើសប្រព័ន្ធបច្ចេកទេសប្រសើរបំផុត ........ 3-9
Table 3-10: ចំណាត់ថ្នាក់សំណល់រឹង ........ 3-8
Table 3-11: វិសាលភាពតំបន់ស្នើឡើងនូវតួនាទី និងការទទួលខុសត្រូវរវាងសាលាក្រុង និងស៊ិនទ្រី ........ 3-11
Table 3-12: តួលេខគោលដៅនៃផែនការមេគ្រប់គ្រងសំណល់រឹងក្នុងភ្នំពេញ ........ 3-12
Table 3-13: យុទ្ធសាស្ត្រដើម្បីសំរេចគោលដៅផែនការមេគ្រប់គ្រងសំណល់រឹង ........ 3-14
Table 3-14: កម្មវិធីអនុវត្ត ........ 3-35
Table 3-15: ថ្លៃដើមគំរោងសំរាប់ផែនការមេ ........ 3-35
Table 3-16: ថ្លៃប្រមូល/ដឹកជញ្ជូនសំណល់រឹងក្រុង និងប្រតិបត្តិការណ៍នៅទីលាន ស្ទ.ម.ជ ដោយ រ.គ.ស.ភ ........ 3-36
Table 3-17: បុរេល័ក្ខណ្ឌរបស់គំរោង ........ 3-36
Table 3-18: អត្រាថ្លៃប៉ាន់ស្មានសំរាប់ការប្រមូលកាកសំនល់រឹងនៅតាមគេហដ្ឋាន ........ 3-39
Table 3-19: អត្រាថ្លៃប៉ាន់ស្មានសំរាប់ការគ្រប់គ្រងកាកសំនល់រឹងនៅតាមគេហដ្ឋាន ........ 3-39
Table 3-20: ការប្រៀបធៀបករណីមាន និងគ្មានជំនួយលើអត្រាថ្លៃដែលត្រូវការ ........ 3-39
Table 3-21: ការសន្និដ្ឋានលើបរិមាណសំណល់ដែលចាក់ចោលដោយ រ.ក.ស.ភ និងស៊ិនទ្រី ........ 3-40
Table 3-22: អត្រាថ្លៃប្រមូលសេវាដោយ រ.ក.ស.ភ ........ 3-41
Table 3-23: អត្រាថ្លៃទីលានដែលត្រូវបង់ដោយគ្រួសារ ........ 3-42
Table 3-24: អត្រាថ្លៃទីលានដែលត្រូវបង់ដោយគ្រួសារ ........ 3-42
Table 3-25: ឆន្ទះ និងលទ្ធភាពរបស់គ្រួសារសំរាប់បង់ថ្លៃសេវានៅឆ្នាំ ២០០៣ ........ 3-42
Table 3-26: ការទស្សន៍ទាយពីលទ្ធភាពនៃការបង់ថ្លៃសេវាដោយគ្រួសារនិមួយ ៗ ........ 3-43
Table 4-1: ផែនការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ និងស្ថាប័នទទួលខុសត្រូវ ........ 4-2
Table 4-2: ការវិភាគលើប៉ារ៉ាម៉ែត្រនីមួយ ៗ ........ 4-8

Table 4-3: ខ្លឹមសារសំខាន់ៗនៃតំបន់គោលដៅនៃការសាកល្បង ........4-13
Table 4-4: ការកែលំអផ្លូវចូលនៅក្នុងតំបន់សាកល្បង ........4-14
Table 4-5: លទ្ធផលនៃការប្រមូលថ្លៃសេវា (ខែមករា ២០០៤) ........4-16
Table 4-6: តំបន់ និងចំនួនប្រជាពលរដ្ឋ ២០០៣ ........4-17
Table 4-7: ចំនួនអតិថិជនតាមសង្កាត់ ........4-17
Table 4-8: បរិមាណសំនល់ដែលត្រូវប្រមូលតាមតំបន់ ........4-18
Table 4-9: លទ្ធភាពប្រមូលសំនល់របស់រដ្ឋាករ........4-19
Table 4-10: កាលវិភាគ ........4-20
Table 4-11: បរិមាណសំនល់នៅ ៤សង្កាត់ ........4-21
Table 4-12: ចំនួនអតិថិជន កិច្ចសន្យា និងបរិមាណប្រមូល ........4-21
Table 5-1: ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈគំរោងសាកល្បងដើម្បីកែលំអទីលាន ........5-2
Table 5-2: ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈគំរោងសាកល្បងដើម្បីកែលំអប្រព័ន្ធប្រមូលសំរាម ........5-3
Table 5-3: ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈគំរោងសាកល្បងលើការអប់រំសាធារណ........5-5
Table 5-4: ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈកាធ្វើសិក្ខាសាលា........5-7
Table 6-1: បរិមាណចាក់ដែលបានប៉ាន់ស្មាន........6-2
Table 6-2: ផ្ទៃហេដ្ឋារចនាសម្ព័នតាមផ្នែកដែលត្រូវសាងសង់ ........6-3
Table 6-3: តារាងគ្រឿងចក្រសំរាប់ទីលាន ........6-4
Table 6-4: តារាងបុគ្គលិកប្រតិបត្តិការណ៍ទីលាន........6-4
Table 6-5: តារាងបុគ្គលិកប្រតិបត្តិការណ៍ធ្វើជីកំប៉ុស្ត........6-5
Table 6-6: ផែនការត្រួតពិនិត្យទីលានដង្កោ........6-6
Table 6-7: ផែនការតម្លៃដើមគំរោងទីលានចាក់សំរាមដង្កោ (១,000ដុល្លាសហរដ្ឋ)........6-7
Table 6-8: បុរេលក្ខ័ណ្ឌសំរាប់ការវាយតំលៃលើផ្នែកហិរញ្ញវត្ថុរបស់គំរោង........6-13
Table 6-9: អត្រាថ្លៃចាក់សំរាមនៅទីលាន និងលទ្ធភាពនៃហិរញ្ញវត្ថុ ........6-14
Table 6-10: បុរេលក្ខ័ណ្ឌសំរាប់ការវាយតំលៃលើផ្នែកហិរញ្ញវត្ថុរបស់គំរោងធ្វើជីកំប៉ុស្ដិ៍........6-15
Table 6-11: EIRR នៃគំរោងធ្វើជីកំប៉ុស ........6-16
Table 6-12: ប្រជាជនដែលបានទទួលសេវាកម្មពីរដ្ឋាករប្រមូលសំនល់ ........6-18
Table 6-13: បរិមាណប្រមូលដែលបានធ្វើផែនការ........6-19
Table 6-14: ការប្រើប្រាស់គ្រឿងចក្រ និងវិធីសាស្រ្តប្រមូលសំរាម........6-19
Table 6-15: គ្រឿងចក្រប្រមូលសំខាន់ៗ........6-20
Table 6-16: មន្រ្តីតំរូវការសំរាប់ការងារប្រមូលសំរាម ........6-21
Table 6-17: ការវិនិយោគធនធានដែលត្រូវការសំរាប់ការពង្រីកសេវាកម្មប្រមូលសំរាម (១,000ដុល្លា) ........6-22
Table 6-18: តំលៃប្រតិបត្តិការណ៍ និងការគ្រប់គ្រង (១,000ដុល្លា)........6-22
Table 6-19: តំលៃសំរាប់ការប្រមូលសំរាម(១,000ដុល្លា) ........6-23
Table 6-20: តំលៃក្នុងមួយឯកតា........6-23
Table 6-21: បុរេលក្ខខ័ណ្ឌនៃការវាយតម្លៃហិរញ្ញវត្ថុ........6-25
Table 6-22: លទ្ធភាពហិរញ្ញកិច្ច និងអត្រាថ្លៃសេវា........6-26
Table 6-23: អត្រាប៉ាន់ស្មានសំរាប់គេហដ្ឋាន........6-26
Table 6-24: ការប៉ាន់ប្រមាណអត្រាតំលៃនៃការប្រមូលសំណល់សំរាប់គេហដ្ឋាន........6-27

Table 6-25: តំលៃគំរោងនៃការបិទទីលានស្ទឹងមានជ័យ (១,000ដុល្លា) ........ 6-31
Table 6-26: ចំនួនអ្នករើសសំរាមនៅទីលានតាមការសង្កេត ........ 6-32

# បញ្ជីរូបភាព

Page:

Figure 1-1: ឋានានុក្រមផែនការ ........ 1-4
Figure 2-1: លំហូរសំណល់ឆ្នាំ ២000៣ ........ 2-7
Figure 3-1: លំហូរសំណល់ក្នុងឆ្នាំ ២00៧ ........ 3-24
Figure 3-2: លំហូរសំណល់ក្នុងឆ្នាំ ២0១២ ........ 3-25
Figure 3-3: លំហូរសំណល់ក្នុងឆ្នាំ ២0១៥ ........ 3-26
Figure 3-4: ទីតាំងទីលានដង្កោ ........ 3-32
Figure 3-5: រូបភាពភូមិសាស្ត្រតំបន់ដែលត្រូវជ្រើសរើស ........ 3-33
Figure 3-6: ការផ្លាស់ប្តូរដីសំរាប់ទីលានថ្មី ........ 3-34
Figure 4-1: ផែនការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធនៅស្ទឹងមានជ័យ ........ 4-3
Figure 4-2: ការពង្រីកតំបន់ចាក់សំរាមស្ទឹងមានជ័យ ........ 4-6
Figure 4-3: The Picture of Samples ........ 4-9
Figure 4-4: Algae grown in the treated leachate ........ 4-9
Figure 4-5: សំណើរប្លង់ជីកសំរាមចាស់ និងផ្លូវចូល ........ 4-12
Figure 4-6: ផែនទីទីតាំងនៃទំបន់សាកល្បងដែលបានជ្រើសរើស ........ 4-14
Figure 4-7: អត្រាប្រមូលប្រាក់ ........ 4-16
Figure 4-8: តំបន់គំរោងសាកល្បង ........ 4-17
Figure 4-9: រថយន្តប្រមូលដែលជាកម្មសិទ្ធរបស់រដ្ឋាករ ........ 4-19
Figure 4-10: Project Site in Sangkat Monorom ........ 4-22
Figure 4-11: Project Site in Sangkat Boeung Trabek ........ 4-22
Figure 6-1: ប្លង់ផែនការរៀបចំទីលានចាក់សំរាមថ្មីដង្កោ (ដំណាក់កាលទី **1**) ........ 6-3
Figure 6-2: ចំណុចត្រួតពិនិត្យ ........ 6-6
Figure 6-3: ប្លង់រោងជាងជួសជុល ........ 6-20
Figure 6-4: ប្រពន្ធ័ប្រមូលថ្លៃសេវា ........ 6-22
Figure 6-5: ទ្រង់ទ្រាយចុងក្រោយនៃទីលានស្ទឹងមានជ័យ ........ 6-29

# បញ្ជីអក្សរកាត់

| | |
|---|---|
| ផ.ស | ផែនការសកម្មភាព |
| ស.ភ | សមភាគីការងារ |
| វ.អ.ធ.ក | វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា |
| ព.រ.ប | ពង្រាងរបាយការណ៍បញ្ចប់ |
| ទ.ច.ដ | ទីលានចាក់សំរាមដង្កោ |
| ម.ប.ស្ថ.ភ | មន្ទីរបរិស្ថានរាជធានីភ្នំពេញ |
| ស.ក.ភ.ព | មន្ទីរសាធារណៈការ និងដឹកជញ្ជូន |
| វ.ហ.ប | ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| អេហ្វ.អេ.អូ | អង្គការស្បៀងអាហារ និងកសិកម្ម |
| ល.ស | លទ្ធភាពសិក្សា |
| រ.ប | របាយការណ៍បញ្ចប់ |
| ស.ឧ.គ្រ | សំណល់ឧស្សាហកម្មគ្រោះថ្នាក់ |
| រ.ដ | របាយការណ៍ដំបូង |
| រ.ប.អ | របាយការណ៍បណ្តោះអាសន្ន |
| ត្រ.ប.ដ | ការត្រួតពិនិត្យបរិស្ថានជំហានដំបូង |
| ស.ឧ | សំណល់ឧស្សាហកម្ម |
| គ្រ.ស.ឧ | ការគ្រប់គ្រងសំណល់ឧស្សាហកម្ម |
| ទ.ស.អ.ជ | ទីភ្នាក់ងារសហប្រតិបត្តិការណ៍អន្តរជាតិជប៉ុន |
| ក.ប្រ | កំណត់ហេតុអង្គប្រជុំ |
| ក្រ.ប.ស្ថ | ក្រសួងបរិស្ថាន |
| ក្រ.អ.យ.ក | ក្រសួងអប់រំ យុវជន និងកីឡា |
| ក្រ.ស | ក្រសួងសុខាភិបាល |
| ផ.ម | ផែនការមេ |
| ស.ក្រ.ភ | សាលាក្រុងភ្នំពេញ |
| ស.ក្រ | សំណល់ក្រុង |
| ស.ឧ.គ.គ្រ | សំណល់ឧស្សាហកម្មគ្មានគ្រោះថ្នាក់ |
| ក.ក.ជ | កម្មវិធីកែលំអអ្នកជិតខាង |
| ប្រ.ថ | ប្រតិបត្តិការណ៍ និងថែទាំ |
| គ.ស | គំរោងសាកល្បង |
| រ.គ.ស.ភ | រដ្ឋាករគ្រប់គ្រងសំណល់រាជធានី |
| រ.វ | របាយការណ៍វិវឌ្ឍន៍ |
| ស្ទ.ស | ការស្ទង់មតិសាធារណៈ |
| ស.ប.ស | ការសិក្សាពីបរិស្ថានសង្គម |
| ក្រ.ជ.ខ | ក្រុមជួយខ្លួនឯង |
| ស្ទ.ម.ជ | ស្ទឹងមានជ័យ |
| ទ.ស្ទ.ម.ជ | ទីលានចាក់សំរាមស្ទឹងមានជ័យ |
| ទ.ក | ទិដ្ឋភាពទំហំការងារ |
| ស.ព.ស.រ | ការសិក្សាពីពេលវេលា និងសកម្មភាពរថយន្ត |
| គ.អ.ភ | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| ស.ប.ស.ស | ការសិក្សាលើបរិមាណ និងសមាសភាពសំណល់ |
| អ.ស.ព | អង្គការសុខភាពពិភពលោក |

# 1 គំរោងការសិក្សា

## 1.1 ប្រវត្តិ

រាជធានីភ្នំពេញ ជាទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា មានប្រជាជន ១,២លាននាក់ ក្នុងឆ្នាំ ២០០៣ (ប៉ាន់ស្មាន) និងមានផ្ទៃដីសរុបប្រហែល ៣៧៤គ.ម[២] ។ ការគ្រប់គ្រងសំណល់រឹង ក្នុងរាជធានីភ្នំពេញស្ថិតនៅក្រោមយុត្តាធិការរបស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនរាជធានី (ស.ក.ភ.៣) ។ សេវាគ្រប់គ្រងនេះ ត្រូវបានផ្តត់ផ្គង់ដោយអង្គភាពសំអាតក្រុងដែលថិតនៅក្រោម ស.ក.ភ.៣ រហូតដល់ខែមិថុនា ឆ្នាំ១៩៩៤ ។ ក្រោយមកដោយសារតែសមត្ថភាពគ្រប់គ្រងសំណល់រឹងក្រុងនៅមានកំរិត សាលាក្រុងក៏បានធ្វើកិច្ចព្រមព្រៀងប្រគល់សិទ្ធិផ្តាច់មុខ ទៅឱ្យអ្នកម៉ៅការឯកជន ក្នុងការផ្តល់សេវាគ្រប់គ្រងនេះ ។ ប៉ុន្តែក្រុមហ៊ុនផ្តល់សេវានេះត្រូវខានផ្លាស់ប្តូរអស់ ៦លើកទៅហើយដោយសារតែជួបវិបត្តិហិរញ្ញវត្ថុ ។

ក្នុងកាលទេសៈបែបនេះ ការពង្រឹងសមត្ថភាពស្ថាប័ន និងកម្មវិធីកែលំអលើកស្ទួយដល់អ្នកជិតខាង (ឧបត្ថមដោយអង្គការណ័រវេ (ICB & NIP by NORAD) ត្រូវបានដឹកនាំធ្វើតាំងពីឆ្នាំ ១៩៩៧ រហូតដល់ខែមិនា ឆ្នាំ២០០២ ដែលជាផ្នែកមួយរបស់ប្រព័ន្ធប្រឡាយបង្ហូរទឹកស្អុយគាំទ្រដោយ ADB នៅក្រោមគំរោងស្តីពីប្រព័ន្ធបង្ហូរ និងការផ្គត់ផ្គង់ទឹកស្អាតរាជធានីភ្នំពេញ និងក្រោមសហហិរញ្ញប្បទានដោយទីភ្នាក់ងារអភិវឌ្ឍន៏សហប្រតិបត្តិការណ៏ន័រវេ (NORAD) ។

ផ្អែកទៅតាមសំណើនៅក្នុង ICB & NIP ដែលផ្តល់ឱ្យដោយ ណ័រវេ សាលាក្រុងភ្នំពេញខានបង្កើតឡើងនូវរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ (រ.គ.ស.ភ) តាមរយៈការបញ្ចូលគ្នារវាងអង្គភាពសំអាតក្រុងភ្នំពេញជាមួយអង្គភាពគ្រប់គ្រងសំណល់រាវភ្នំពេញក្នុងឆ្នាំ ២០០១ ។ ស្ថានភាពផ្តាច់មុខនេះត្រូវបានធ្លាក់ចុះខ្សោយក្នុងពេលដែល រ.គ.ស.ភ បានចាប់ផ្តើមសេវាប្រមូលសំរាមនៅក្នុងតំបន់ NIP និងចាប់ផ្តើមធ្វើប្រតិបត្តិការណ៏នៅទីលានចាក់ សំរាមស្ទឹងមានជ័យ ។ ប៉ុន្តែ កិច្ចសន្យាដែលបានធ្វើរវាងសាលាក្រុងភ្នំពេញជាមួយក្រុមហ៊ុនស៊ីនទ្រីបានកំណត់ឱ្យតំបន់ដែលផ្តល់សេវាប្រមូលសំរាមមានតែក្នុងតំបន់ NIP ដែលគិតទៅមានតិចជាង ២%នៃចំនួនប្រជាជនសរុបក្នុងរាជធានីភ្នំពេញ។

ជាទូទៅសេវាប្រមូលសំរាមក្នុងក្រុងត្រូវានកែលំអតាមរយៈក្រុមហ៊ុនឯកជនដែលមានបច្ចុប្បន្ន ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយមានតំបន់ជាច្រើនក្នុងក្រុងនៅមិនទាន់មានសេវាប្រមូលគ្រប់គ្រាន់ ហើយមានសំរាមរាប់តោនត្រូវបានចាក់ចូលទៅក្នុងស្ទឹង និងស្រះទឹក ដុត ឬទុកចោលដោយមិនបានប្រមូលដែលធ្វើឱ្យមានការពង្រាយតាមរយៈសត្វពាំធ្វើឱ្យស្ទះ ដល់ប្រព័ន្ធបង្ហូរ និងបង្កើតនូវស្ថានភាពគ្មានអនាម័យ ។ ការប្រមូលសំរាមនេះមានភាពខ្សោយនៅតាមតំបន់ជាយក្រុង និង នៅតាមតំបន់សំណង់អនាធិបតេយ្យជាច្រើនក្នុងក្រុងដែលជាទីជំរករបស់គ្រួសារក្រីក្ររាប់ពាន់នាក់ ។ ទីលានចាក់សំរាមស្ទឹងមានជ័យ ជាទីលានតែមួយគត់របស់ទីក្រុងនេះ ហើយដែលមានប្រតិបត្តិការណ៏ការមិនទៀងទាត់អស់រយៈពេល ៣៨ ឆ្នាំគិតចាប់ពីឆ្នាំ ១៩៦៥ មកម្ល៉េះ ។ ដោយសារតែផ្ទៃដីទីលាននេះមានកំណត់ (តែ ៦,៨ហ.ត) ហើយដែលសំរាមត្រូវនចាក់គររហូតដល់កំពស់ជាង ៩ម៉ែត្រ ជាមធ្យម ប្រតិបត្តិការទីលានកាន់តែជួបការលំកខ្លាំងឡើងៗ ។ សមត្ថភាពផ្ទុករបស់ទីលាននេះមាននៅសល់ប្រហែលតិចជាង ២ឆ្នាំទៀតប៉ុណ្ណោះ ហើយដែលការតាំងទីលំនៅរបស់អ្នកស្រុកនៅក្បែរ ឬជិតជាង ១០០ម ពីទីលាន ដោយសារតែកំណើនទីប្រជុំជន ។ ការកសាងទីលានចាក់សំរាមថ្មីគឺជាតំរូវការចាំបាច់បន្ទាន់ ។ ទីលានដែលមាននេះជាប្រភេទទីលានចាក់ដោយចំហរហើយដែលមានអ្នករើសសំរាមជាង ៥០០នាក់ ធ្វើការជាប្រចាំនៅទីនោះដោយគ្មានបទបញ្ញត្តិ ឬការត្រួតពិនិត្យបង្កជាហេតុប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថានជុំវិញដូចជា ការបំពុលខ្យល់តាមរយៈផ្សែងដែលហុយចេញពីភ្លើងឆេះទីលាន ការ ពង្រាយសំរាមក្លិនស្អុយ និងការបំពុលទឹកលើដី និង ទឹកក្រោមដី។ល។ ដើម្បីជំនះភាពលំបាកដូចដែលបានជំរាបពីខាងលើលើការគ្រប់គ្រង

សំណល់រឹងក្នុងក្រុងភ្នំពេញ ផែនការទូលំទូលាយនៃវិធានការដោះស្រាយមួយ ចំនួនរួមទាំងការ ប្រើប្រាស់កម្លាំងកាយ និងប្រាជ្ញា នឹងត្រូវលើកយកមកអនុវត្ត ។

ក្នុងន័យនេះ រដ្ឋាភិបាលជប៉ុនបានបញ្ជូនជំនាញការរបស់ខ្លួនផ្នែកគ្រប់គ្រងសំណល់រឹងមកពីរលើកសំរាប់រយៈពេលខ្លី គឺក្នុងខែតុលា ឆ្នាំ២០០០ និងខែមិថុនា ឆ្នាំ២០០១ ម្តងទៀត ដើម្បីធ្វើការវាយតម្លៃស្ថានភាពនេះ ដូចដែលរាជរដ្ឋាភិបាលកម្ពុជាបានស្នើ ។

រាជរដ្ឋាភិបាលកម្ពុជា បានស្នើដល់រដ្ឋាភិបាលជប៉ុនដើម្បីអនុវត្តលើការសិក្សានេះ ក្នុងឆ្នាំ ២០០០ ។ ឆ្លើយតបទៅនឹងសំណើនេះភាគីជប៉ុន ក៏បានបញ្ជូនក្រុមសិក្សា JICA របស់ខ្លួនមកសិក្សាជាជំហានដំបូងក្នុងកម្ពុជា ហើយដែលទិដ្ឋភាពទំហំការងារត្រូវបានចុះហត្ថលេខាយល់ព្រមដោយរដ្ឋាភិបាលទាំងពីរ កាលពីថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០២ ។ ជាបន្ទាប់ មកទៀតទើបភាគីខាង JICA ជ្រើសរើសក្រុមហ៊ុន Kokusai Kogyo Co., Ltd ធ្វើជាទីប្រឹក្សាក្នុងការដឹកនាំធ្វើការ សិក្សានេះ ។

## 1.2 គំរោងសិក្សា

ការសិក្សាបានចាប់ផ្តើមនាខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលមានរយៈពេលកំណត់ប្រមាណ ១៦ខែ ។ រយៈពេលសិក្សាត្រូវបានចែកជា ២ តំណាក់កាល ។ ក្រុមសិក្សាបានរៀបចំផែនការមេនាតំណាក់កាលទី ១ ដោយយោងទៅលើការយល់ដឹងលើស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងកាកសំណល់រឹង និងការទស្សទាយលើ លំហូរសំណល់នាពេលអនាគត ។ នាតំណាក់កាលទី ២ ក្រុមសិក្សាបានធ្វើការសិក្សាពីការសាកល្បងគំរោងអទិភាពមួយចំនួនដោយជ្រើសរើសពីផែនការមេគឺការកសាងទីលានថ្មីដង្កោ ការពង្រីកសេវាកម្មប្រមូលសំរាម និងការបិតទីលានចាស់ស្ទឹងមានជ័យ ។ ជាងនេះទៀត ក្រុមសិក្សាបានអនុវត្តន៏គំរោងសាកល្បងជាច្រើន រាប់បញ្ចូលទាំងការកែលំអរទីលានចាស់ កែលំអរប្រព័ន្ធប្រមូលសំរាម អភិវឌ្ឍន៏ និងជំរុញទីផ្សាជីកំប៉ុស និងការរៀបចំប្រព័ន្ធទិន្នន័យសំរាប់ការគ្រប់គ្រងកាកសំណល់រឹង ។

ចំពោះការអភិវឌ្ឍន៏ទីលានចាក់សំរាមថ្មី សាលាក្រុងភ្នំពេញបានរៀបចំការជួបជុំជាសាធារណពីរលើកនៅក្នុងតំណាក់កាលទី ២ នៃគំរោងដោយយោងលើលទ្ធផលនៃផែនកាតំបូង និងការសិក្សាលើផលប៉ះពាល់បរិស្ថានដោយក្រុមសិក្សា JICA ។ នេះជាបញ្ហាគន្លឹះដែលសាលាក្រុងបានគិតគូរដល់អាយុកាលកំណត់នៃទីលានចាស់ និងការងាររៀបចំទីលានថ្មី ។ ទោះបីជាសាលាក្រុងបានទិញដីសំរាប់ការសាងសង់ទីលានថ្មីក្តី តែទំហំនោះមិនបានគ្រប់គ្រាន់តាមផែនការសិក្សាទេ ដោយសារកំណើនថ្លៃដីយ៉ាងឆាប់រហ័សតាមបណ្តោយផ្លូវជាតិលេខ ៣០៣ ។ ប្រហែលមកពីបញ្ហាថាផែនការជៀវដីនេះត្រូវបានផ្សព្វផ្សាយនាពេលជួបជុំជាសាធារណ ដែលធ្វើអោយតំលៃដីបានកើនឡើងហួសពីកំរិតទឹកប្រាក់អនុម័តដោយរាជរដ្ឋាភិបាល ។ ដូច្នេះ សាលាក្រុងបានទិញដី ២០ ហ.ត ជាប់និងដីចាស់ទំហំ ១១ ហ.ត ចំងាយប្រមាណ ៨០០ ម ពីខាងលិចផ្លូវជាតិលេខ ៣០៣ ។ ដូច្នេះ ដីសរុបមានប្រមាណ ៣១.៤ ហ.ត ។ ដូច្នេះ គំរោងទីលានត្រូវធ្វើការកែលំអរជាថ្មីតាមទំហំដីនេះ ។

ទោះបីថា ក្រុមហ៊ុន ស៊ិនទ្រីត្រូវផ្តល់សេវាកម្មនាទីក្រុងទាំងមូលតាមកិច្ចសន្យារវាងសាលាក្រុង និងក្រុមហ៊ុនក្តី តែផែនការមេបានស្នើរថា សាលាក្រុង ឬរដ្ឋាករគ្រប់គ្រងសំនល់ត្រូវផ្តល់សេវាកម្មប្រមូលសំណល់នៅខណ្ឌជាយក្រុងទាំងបី រីឯក្រុមហ៊ុននឹងត្រូវធ្វើការលើខណ្ឌប្រជុំជនទាំងបួន ។ តែការស្នើរអោយមានការបែងចែកតំបន់នេះមិនត្រូវបានទទួលការឯកភាពពី ស៊ិនទ្រីទេ ។ ជាងនេះទៀត កំរិតសមត្ថភាពរបស់រដ្ឋាករ និងមន្ទីរបរិស្ថានរាជធានី ក៏ត្រូវបានលើកមកពិចារណាក្នុងការសិក្សានេះដែរ ហើយការកសាងសមត្ថភាពរបស់ស្ថាប័នទាំងនេះ គឺជាការចាំបាច់បំផុត ។ យោងលើតំរូវការកំស្តែងនេះ នាថ្ងៃទី ០៤ ខែ កុម្ភៈ ២០០៤ សាលាក្រុងភ្នំពេញបានស្នើរអោយក្រុមសិក្សាពន្យាពេលនៃការសិក្សាដើម្បីកែតំរូវគំរោងទីលានថ្មី និងការពង្រីកសេវាកម្មប្រមូលសំណល់ការកសាងសមត្ថភាពរបស់រដ្ឋាករ និងការចែកជូនបទពិសោធន៏ពីការសិក្សាដល់ស្ថាប័នពាក់ព័ន្ធ ។ JICA បានឯកភាពលើសំណើរនេះ ហើយបានបន្តគំរោងរហូតដល់ខែ

មិនា ឆ្នាំ ២០០៥ ។ ដូច្នេះ តំណាក់កាលទី ៣ នៃការសិក្សានេះត្រូវបានធ្វើឡើងដើម្បីកែតំរូវផែនការមេ និងការសិក្សាលទ្ធភាពនៃគំរោង និងការកសាងសមត្ថភាពរបស់រដ្ឋាករ ។ ក្រុមសិក្សាបានពិនិត្រឡើងវិញនូវគំរោងទីលានថ្មីដោយយោងលើសេចក្តីសន្និដ្ឋានថា លក្ខណការសិក្សាដីនូវរក្សាលទ្ធផលដូចដែលបានវិភាគនាតំណាក់កាលទី ២ នោះដែរ ព្រោះថាដីថ្មីដែលបានទិញពេលក្រោយនេះគឺជាប់ទៅនិងទីតាំងដីចាស់ស្រាប់ ហើយមានលក្ខណភូមិសាស្ត្រដូចគ្នា។ ប៉ុន្តែ ទោះជាយ៉ាងណាការសិក្សាភូមិសាស្ត្រដីបន្ថែមនោះ បានព្រៀងទុកថានឹងត្រូវសិក្សាម្តងទៀតក្នុងពេល រៀបចំគំរោងកសាងទីលានថ្មី ។

សាលាក្រុងបានរៀបចំធ្វើការជួបជុំសាធារណលើកទីបីដើម្បីទទួលបានការឯកភាពពីប្រជាពលរដ្ឋលើការអនុវត្តទីលានថ្មី ដោយធ្វើការពន្យល់អំពីផែនការដែលបានកែលំអរ ។ សាលាក្រុងក៏ទទួលបានការអនុម័តលើការសិក្សាលើផលប៉ះពាល់បរិស្ថាននាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ។ រីឯការពង្រីកតំបន់ប្រមូលសេវា សាលាក្រុង និងក្រុមហ៊ុនស៊ីនទ្រី នាថ្ងៃទី ១២ ខែមេសា ឆ្នាំ ២០០៤ បានឯកភាពលុបបំបាត់តំបន់ដែលមិនមានសេវាកម្ម និងតំបន់ដែលមានសេវាកម្មតែមិនទាន់សមស្រប ដោយយោងលើកិច្ចសហការគ្នាទៅវិញទៅមក ។ ព្រមជាមួយនោះ ភាគីទាំងពីរបន្តរួមគ្នាកំណត់តំបន់ដែលមិនមានសេវាកម្ម ។ តែទោះជាយ៉ាងណា ភាគីទាំងពីរមិនអាចបញ្ចប់ការចរចារលើតំបន់សេវាកម្មទេរហូតដល់ខែ កុម្ភៈ ឆ្នាំ ២០០៥ នេះ ។

ដោយហេតុនេះ នាថ្ងៃ ០៣ ខែមិនា ឆ្នាំ ២០០៥ សាលាក្រុងភ្នំពេញបានស្នើរអោយក្រុមសិក្សាធ្វើការបញ្ចប់របាយការណ៍នេះ និងការសិក្សាលើលទ្ធភាពគំរោងជំនួយដោយយោងលើការសន្និដ្ឋានថា រដ្ឋាករនឹងផ្តល់សេវាកម្មលើតំបន់ដែលក្រុមសិក្សាយល់ថាមិនមានសេវាកម្មប្រមូលសំនល់ដោយក្រុមហ៊ុនឯកជន ។ ដូច្នេះ របាយការណ៍នេះត្រូវបានរៀបចំដោយយោងលើការសើរសុំនោះ ។

ក្រុមសិក្សាបានធ្វើគំរោងការសាកល្បងដោយរាប់បញ្ចូល ការបន្តគំរោងកែលំអរទីលានចាស់ ការពង្រីកតំបន់ប្រមូលសំណល់លើ ៤ សង្កាត់ (សេណារីយ៉ូ ១) និងការកសាងសមត្ថភាពរបស់រដ្ឋាករ និងមន្ទីរបរិស្ថាន ។ ជាងនេះទៀត ក្រុមសិក្សាបានរៀបចំវគ្គបណ្តុះបណ្តាលពាំពីការសិក្សាលើផែនការមេនេះដល់ថ្នាក់ខេត្តដើម្បីអោយទីប្រជុំជនខេត្តអាចបន្តផ្តល់កាយល់ដឹងនេះជាបន្តដល់អ្នកដែលមិនបានចូលរួម ។

## 1.3 គោលបំណង និងតំបន់សិក្សា

### 1.3.1 គោលបំណង

(ក) បង្កើតផែនការមេ (បន្ទាប់ទៅនេះមានអក្សរកាត់គឺ "ផ.ម") គ្រប់គ្រងសំណល់រឹងក្នុងភ្នំពេញជាមួយឆ្នាំគោលដៅ ២០១៥ ។

(ខ) ដឹកនាំការសិក្សាលទ្ធភាព(បន្ទាប់ទៅនេះមានអក្សរកាត់គឺ "ស.ល")សំរាប់ជ្រើសរើសគំរោងជាអាទិភាព ។

(គ) ផ្ទេរបច្ចេកវិទ្យាដល់សមភាគី (បន្ទាប់ទៅនេះមានអក្សរកាត់គឺ "ស.ភ") នៅក្នុងវគ្គសិក្សា ។

### 1.3.2 តំបន់សិក្សា

តំបន់សិក្សារួមបញ្ចូលនៅក្នុងទីក្រុងទាំងមូល(ប្រជាជនប្រហែល១,២លាននាក់ និងផ្ទៃ៣៧៣,៧៣ គ.ម$^{២}$) ។

### 1.3.3 សំណល់ដែលមានក្នុងតំបន់សិក្សា

សំណល់នៅក្នុងតំបន់សិក្សាមាន សំណល់ទីក្រុង សំណល់ស្អុយ (ភក់ប្រមូលចេញអំពីអាងទឹកស្អុយ) សំណល់ឧស្សាហកម្ម និងសំណល់វេជ្ជសាស្ត្រ។ សំណល់ក្នុងក្រុង គឺជាប្រភេទសំណល់មិនឆេះ សំណល់ងាយឆេះ និងសំណល់សំពីងសំពោងធំដុំដែលមាននៅក្នុងក្រុង ហើយដែលអាចចែកចេញជា ៥ប្រភេទ ទៅតាមប្រភពបង្កើតរបស់ វាតួយ៉ាងដូចជា សំណល់តាមផ្ទះ សំណល់អាជីវកម្ម សំណល់ពីកន្លែងធ្វើការ សំណល់ទីផ្សារ និងសំណល់បោសសំអាត តាមផ្លូវ ។ ក្រុមសិក្សាដឹកនាំការងារសិក្សាលើបរិមាណ និងសមាសភាពសំណល់ភក់ សំណល់ឧស្សាហកម្ម និងវេជ្ជសាស្ត្រ ដែលត្រូវបានយកទៅចាក់ចោលនៅទីលានចាក់ចុងក្រោយ ។ ប៉ុន្តែទោះបីយ៉ាងណា ក៏ក្រុមសិក្សានឹងមិនផ្តោតទាំងស្រុង ទៅលើប្រភេទសំណល់ទាំងបីទៅក្នុង ផ.ម ឡើយ ប៉ុន្តែនឹងត្រូវបញ្ជាក់នូវស្ថានភាពបច្ចុប្បន្ន កំណត់បញ្ហាដែលត្រូវដោះស្រាយ និងលើកស្នើលទ្ធភាពដំណោះស្រាយដែលអាចធ្វើទៅរួចវិញ ។

## 1.4 គោលនយោបាយគ្រឹះនៃការសិក្សា

នៅក្នុងគំរោងរបស់ ណ្យូវ៉ាដ លើការកសាងសមត្ថភាពស្ថាប័ន និងក្នុងតំបន់ NIP "ផែនការយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង និងផែនការសកម្មភាព (ផ.យ.គ្រ.ស.រ ផ.ស.) ទាមទារជាចំបងត្រូវរៀបចំផែនការប្រតិបត្តិការណ៍ដែលពាក់ព័ន្ធនឹងប្រតិបត្តិការណ៍ និងការគ្រប់គ្រងសេវាស្ថាប័ន និងការងារជាក់ស្តែង ដែលជាជំហានបន្ទាប់ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ក្នុងភ្នំពេញ ។

Figure 1-1: ឋានានុក្រមផែនការ




យោងតាម "ផែនការយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង និងផែនការសកម្មភាព (ផ.យ.គ្រ.ស.រ ផ.ស.) ដែលបង្កើតដោយណ្យូវ៉ាដ លើការកសាងសមត្ថភាពស្ថាប័ន/តំបន់ NIP ដូចមានបញ្ជាក់ពីខាងលើ ការសិក្សានេះត្រូវបានអនុវត្តដោយសង្កត់ធ្ងន់ទៅលើការបង្កើតផែនការប្រតិបត្តិការណ៍ជាក់ស្តែងសំរាប់ការគ្រប់គ្រងសំណល់រឹង ។

គោលនយោបាយគ្រឹះនៃការសិក្សាមានដូចតទៅ :

- បង្កើតផែនការអនុវត្តគ្រប់គ្រងសំណល់រឹង (លទ្ធភាពជាក់ស្តែង)
- លើកស្ទួយការអភិវឌ្ឍន៍សមត្ថភាពសំរាប់សកម្មភាពចំបងៗលើការគ្រប់គ្រងសំណល់រឹង (កសាងសមត្ថភាព)
- អភិវឌ្ឍន៍ និងប្រើប្រាស់បច្ចេកវិទ្យាសមស្រប (បច្ចេកវិទ្យាសមស្រប)
- លើកស្ទួយការចូលរួមសាធារណៈ (ការចូលរួមសាធារណៈ)
- លើកស្ទួយកសាងឱ្យមានកិច្ចព្រមព្រៀងគ្នាក្នុងចំណោមអ្នកពាក់ព័ន្ធ (ការព្រមព្រៀងគ្នា)

# 1.5 ពេលវេលានៃការសិក្សា

ផ្អែកតាមទិដ្ឋភាពនៃទំហំការងារ (ទ.ក) ដែលបានឯកភាពគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និង JICAការសិក្សាបានចាប់ផ្តើមក្នុងខែកុម្ភៈ ឆ្នាំ២០០៣ ហើយដែលការចុះសិក្សានៅមូលដ្ឋានផ្ទាល់ត្រូវបានបញ្ចប់ក្នុងខែមករា ឆ្នាំ ២០០៥ ។ ការសិក្សានេះបានអនុវត្តទៅជា ៣ ដំណាក់កាលដូចខាងក្រោមនេះ :

**ដំណាក់កាលទី ១:** ខែកុម្ភៈ ឆ្នាំ២០០៣ ដល់ ខែសីហា ឆ្នាំ២០០៣ ។
សិក្សាទៅលើស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងសំណល់រឹង និងការបង្កើតផែនការមេ ។

**ដំណាក់កាលទី ២:** ខែកញ្ញា ឆ្នាំ២០០៣ ដល់ ខែមិនា ឆ្នាំ២០០៤ សិក្សាទៅលើគំរោងជាអាទិភាពនានា ។

**ដំណាក់កាលទី ៣:** ឧសភា ២០០៤ ដល់ខែ មិនា ឆ្នាំ ២០០៥ ។

# 1.6 ការរៀបចំការសិក្សា

ការសិក្សានឹងត្រូវបានអនុវត្តក្នុងនាមជាសហការងាររវាង JICA និងសមភាគី ស.ភ ។

## 1.6.1 សមាជិកក្រុមសិក្សា

| ឈ្មោះ | តួនាទី និងជំនាញ |
|---|---|
| Mr. Junji Anai | ប្រធានក្រុម- ការរៀបចំផែនការគ្រប់គ្រងសំណល់រឹង |
| Mr. Susumu Shimura | អនុប្រធាន- ការគ្រប់គ្រងស្ថាប័ន |
| Mr. Robert Deutch | រៀបចំផែនការប្រមូល និងដឹកជញ្ជូន |
| Mr. Tamotu Suzuki | ចាក់ចុងក្រោយ/កែច្នៃ/សំណល់វេជ្ជសាស្ត្រ/សំណល់ឧស្សាហកម្ម |
| Ms. Keiko Kani | ពិចារណាលើផ្នែកសង្គម/ចូលរួមសាធារណៈ/អប់រំបរិស្ថាន |
| Mr. Takeshi Higo | បរិមាណ និងសមាសភាពសំណល់/ការពិនិត្យផ្នែកបរិស្ថាន |
| Mr. Satoshi Sugimoto | វិភាគផ្នែកសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| Mr. Masahiro Ido | រៀបចំផែនការសម្ភារៈគ្រឿងចក្រ/ប៉ាន់ស្មានតំលៃ |
| Mr. Kunito Ishibashi | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ/អភិវឌ្ឍន៍វែបសាយ |
| Mr. Masanori Takeishi | ផែនការថែទាំរថយន្ត |
| Mr. Masahiko Takahashi | រដ្ឋបាលគ្រប់គ្រងផ្នែកបណ្តុះបណ្តាល |
| Mr. Tep Makathy | ដឹកនាំក្រុមជំនួយការ និងទទួលបន្ទុកលើការគ្រប់គ្រងកែទំរង់ស្ថាប័នសមភាគី និងការប្រមូល និងដឹកជញ្ជូនសំណល់ |
| Mr. Saing Hay | ជំនួយការទីលាន |
| Ms. Kheang Lyhun | ជំនួយការ-បញ្ហាសង្គម ការចូលរួមសាធារណ និងអប់រំ |

### 1.6.2 សមាជិកជាបុគ្គលិកសមភាគី

| ឈ្មោះ | ចាត់តាំងមកពី |
|---|---|
| លោក. មឿន សុផាន់ | នាយការិយាល័យសាធារណការ ស.ក.ភ.ព សាលាក្រុងភ្នំពេញ |
| លោក. ម៉េង ភូម៉ារិទ្ធ | មន្ត្រី ស.ក.ភ.ព |
| លោក. ខឹម សណ្ដាប់ | មន្ត្រី ស.ក.ភ.ព |
| លោក. ហេង ឡៃអ៊ិន | អភិបាល រ.គ.ស.ភ ( កុម្ភៈ ២០០៣ ដល់មេសា ២០០៤) |
| លោក សៅ គុណឆុន | អភិបាល ( ចាប់តាំងពីខែ ឧសភា ២០០៤) |
| លោក. ឡេង ស៊ីម៉ែន | អភិបាលរង រ.គ.ស.ភ |
| លោក. អ៊ុច វ៉ាន់ | អភិបាលរង រ.គ.ស.ភ ( កុម្ភៈ ២០០៣ ដល់ ខែតុលា ២០០៤) |
| លោក សំ វិច្ឆិកា | អភិបាលរង ( ចាប់តាំងពីខែ តុលា ២០០៤) |
| លោក សួង ផល្លី | អភិបាលរង ( ចាប់តាំងពីខែ ឧសភា ២០០៤) |
| លោក. ទេព សម្បត្តិ | មន្ត្រីផ្នែកគណនេយ្យនៃ រ.គ.ស.ភ |
| លោក ខាត់ ឧសថា | មន្ត្រីផ្នែកគណនេយ្យនៃ រ.គ.ស.ភ |
| អ្នកនាង លី ថាវី | មន្ត្រីផ្នែកគណនេយ្យនៃ រ.គ.ស.ភ |
| កញ្ញា. ណៃ រដ្ឋា | មន្ត្រីផ្នែកធ្វើផែនការនៃ រ.គ.ស.ភ |
| កញ្ញា. ហែម វិសាល | មន្ត្រីផ្នែករដ្ឋបាលនៃ រ.គ.ស.ភ |

## 1.7 ការផ្ទេរបច្ចេកវិទ្យា

ក្រុមសិក្សាបានផ្ទេរបច្ចេកវិទ្យាជូនដល់ ស.ភ តាមរយៈការអនុវត្តន៏រាល់ការងារសិក្សាដោយសហការជាមួយ ស.ភ និងឆ្លងតាមពេលអនុវត្តគំរោងសាកល្បង ។ ជាងនេះទៀតការបណ្ដុះបណ្ដាលសំរាប់ ស.ភ ត្រូវបានធ្វើឡើងនៅក្នុងប្រទេសឡាវ ក៏ដូចជាសិក្ខាសាលាមួយចំនួនក្នុងប្រទេសកម្ពុជា ។ ការផ្ទេរបច្ចេកវិទ្យាត្រូវបានពិភាក្សាលំអិតនៅក្នុងផ្នែកទី ៥ ។

## 1.8 របាយការណ៍

ការសិក្សាបានដាក់ជូនរបាយការណ៍ជាច្រើនដូចមានក្នុងរូបភាពខាងក្រោមនេះ ដោយយោងលើលំដាប់នៃការសិក្សា។

| | ២០០៣ | | | | ២០០៤ | | | | ២០០៥ |
|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ |
| តំណាក់កាលសិក្សា | Phase 1 | Phase 1 | Phase 2 | Phase 2 | | Phase 3 | Phase 3 | Phase 3 | Phase 3 |
| ការដាក់ជូនទូវរបាយការណ៍ | ▲ IC/R | ▲ PR/R(1) | ▲ IT/R | | ▲ PR/R(2) | ▲ DF/R(1) | ▲ PR/R(3) | ▲ DF/R(2) | ▲ F/R |

| អក្សរកាត់ | របាយការណ៍ | មាតិកា |
|---|---|---|
| IC/R | របាយការណ៍តំបូង | មាតិកានៃការសិក្សា និងកាលវិភាគ |
| PR/R (1) | របាយការណ៍តំណាក់កាលទី ១ | ការបកស្រាយលក្ខណតំបូងនៃការសិក្សា និងការរៀបចំសំណើរ |
| IT/R | របាយការណ៏បណ្ដោះអាសន្ន | ពង្រាងផែនការមេ និងការជ្រើរើស គំរោងអទិភាព |
| PR/R (3) | របាយការណ៏តំណាក់កាលទី ២ | ដំណើរការនៃគំរោងការសាកល្បង និងលទ្ធផលបណ្ដោះអាសន្នលើគំរោងអទិភាព |
| DF/R (1) | ពង្រាងរបាយការណ៏បញ្ចប់ ១ | ផែនការមេ និងការសិក្សាលើលទ្ធភាពនៃគំរោងអទិភាព |
| PF/R (3) | របាយការណ៏តំណាក់កាលទី ៣ | ដំណើរការនៃគំរោងការសាកល្បងនិងការបកស្រាយលក្ខណតំបូងនៃការសិក្សាផែនការមេ និងលទ្ធភាពនៃគំរោង |
| DF/R (2) | ពង្រាងរបាយការណ៏បញ្ចប់ ២ | ពង្រាងបញ្ចប់សិក្សាផែនការមេ និងការសិក្សាលទ្ធភាពនៃគំរោង |
| F/R | របាយការណ៏បញ្ចប់ | បញ្ចប់សិក្សាផែនការមេ និងការសិក្សាលទ្ធភាពនៃគំរោង |

របាយការណ៏បញ្ចប់រួមមានរបាយការណ៏ទាំងឡាយដូចខាងក្រោម ។ របាយការណ៏នេះជាភាសារអង់គ្លេសនៃរបាយការណ៏សង្ខេប ២ ។

- សង្ខេប (ជាភាសាជប៉ុន អង់គ្លេស និងខ្មែរ)
- របាយការណ៏ចំបង (ជាភាសាអង់គ្លេស)
- របាយការណ៏ទ្រទ្រង់ (ជាភាសាអង់គ្លេស)
- សៀវភៅទិន្នន័យ (ជាភាសាអង់គ្លេស)

ក្រុមសិក្សាបានដាក់បញ្ចូលគ្នានូវរបាយការណ៏ដូចខាងក្រោម ។

- ផ្នែកទី ១: ស្ថានភាពបច្ចុប្បន្ននៃការគ្រប់គ្រងសំណល់រឹង
-ផ្នែកទី ២: ផែនការមេនៃការគ្រប់គ្រងសំណល់រឹង
-ផ្នែកទី ៣: គំរោងសាកល្បង និងការពង្រឹងសមត្ថភាព
-ផ្នែកទី ៤: ការសិក្សាលើគំរោងសាកល្បង
-ផ្នែកទី ៥: សន្និដ្ឋាន និងការផ្ដល់អនុសាសន៏

សំរាប់ការរៀបចំឯកសារបញ្ចូលគ្នា ឯកសារលំអិតខ្លះមិនត្រូវបានដាក់ចូលក្នុងរបាយការណ៏សង្ខេប និងរបាយការណ៏ចំបងទេ ។ ក្នុងករណីយនេះ សូមអ្នកអានមេត្តាយោងលើឯកសារគាំទ្រ និងសៀវភៅទិន្នន័យ ។

## 1.9 ឯកសារបន្ទុករបស់ JICA លើការពិចារណាលើបរិស្ថាន និងសង្គម

នាឆ្នាំ ២០០៤ អង្គការ JICA បានសំរេចប្រើប្រាស់សៀវភៅបន្ទុក "ឯកសារបន្ទុករបស់ JICA លើការពិចារណាលើបរិស្ថាន និងសង្គម" ចំពោះរាល់គំរោង និងការសិក្សានានា ។ តែដោយសារថា ការសិក្សានេះបានចាប់ផ្តើមនាឆ្នាំ ២០០២ នោះឯកសារបន្ទុកនេះមិនទាន់ត្រូវបានអនុញ្ញាត្តិអោយប្រើប្រាស់ទេ ។ ក្រុមសិក្សាបានស្នើរដល់ក្រុមប្រឹក្សាពិគ្រោះយោបល់លើផ្នែកបរិស្ថាន និងសង្គមដើម្បីពិនិត្យរបាយការណ៍នេះ និងសំរេច ។ ទោះបីជារបាយការណ៍នេះបានឆ្លើយតបទៅនិងយោបល់ណែនាំរបស់ក្រុមប្រឹក្សាពិគ្រោះយោបល់ក្តី តែក្រុមសិក្សាបានផ្តល់យោបល់ថា ចំនុចខ្លះមិនអាចធ្វើបាន ឬមិនមានទិន្នន័យឡើយ ក្នុងកំលុងពេលសិក្សា និងការអនុវត្តន៍ ។

# 2 ស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន

## 2.1 ស្ថានភាពបច្ចុប្បន្ននៅតំបន់សិក្សា

### 2.1.1 បរិស្ថានធម្មជាតិ

ប្រទេសកម្ពុជាជាប្រទេសស្ថិតនៅក្នុងតំបន់ត្រូពិចដែលមានរដូវក្តៅ និងសើម ។ រដូវក្តៅគិតចាប់តាំងពីខែធ្នូដល់ខែមេសា រីឯរដូវវស្សាគឺចាប់ពីខែឧសភា ដល់ខែវិច្ឆិកា ។ បរិមាណភ្លៀងធ្លាក់មានកំរិតលើសពី ១៨០០ មម នៅផ្នែកភាគខាងលិច និងខាងកើតតំបន់ភ្នំ ឬតំបន់ខ្ពង់រាប និងចាប់ពី ១៤០០ រហូតដល់ ១៧០០ មម នៅតាមតំបន់ទំនាប ។ នាទីក្រុងភ្នំពេញ ភ្លៀងធ្លាក់ចាប់ពីខែឧសភារហូតដល់ខែសីហា មានកំរិតកំពស់ប្រមាណ ១៥០ មម ។ កំរិតខ្ពស់បំផុតនោះគឺ ៣០០មម តែក្នុងចន្លោះពីខែកញ្ញា ដល់ខែតុលាតែប៉ុណ្ណោះ ។ សីតុណ្ហភាពអតិបរិមារគឺ ៣៥ អង្សាក្នុងខែមេសា ហើយធ្លាក់ចុះមកដល់ ៣០ អង្សាចន្លោះពីខែវិច្ឆិកា និងខែមករា ។

ស្ថានភាពភូមិសាស្រ្ត និងភូគពសាស្រ្តត្រូវបែងចែកជា តំបន់ខ្ពង់រាបភាគខាងជើង តំបន់ទំនាបភាគខាងកើត តំបន់ខ្ពងរាបនារតី និងតំបន់ទំនាបកណ្តាល ។ តំបន់ខ្ពង់រាបភាគខាងជើងតភជាប់ជាមួយតំបន់ទំនាបកូរាតនៃប្រទេសថៃដែលមានពោរពេញដោយថ្មខ្សាច់សម័យអិនដូនេស៊ីដែលសំបូរជាតិដែក។ តំបន់ទំនាបភាគខាងកើតមានចំរុះដោយថ្មខ្សាច់ពីយុគសម័យមេសូសូអ៊ិច និងគ្របដណ្តប់ដោយថ្មបាសាល់ដោយកន្លែង ។ នៅភ្នំដំរី និងភ្នំក្រវាញ ដែលមានកំពស់ចាប់ពី ៥០០ ដល់ ១៧០០ម មាននៅតំបន់នារតីដែលជាទូទៅសំបូរដោយថ្មមានវ៉ាយវ៉ាយចំណាស់ដូជា ថ្មខ្សាច់ ស៊ីស និងថ្មកំបោរជាដើមដែលបន្សល់ពីយុគសម័យមេសូសូអ៊ិច ។ ផ្នែកទំនាបកណ្តាលហ៊ុំព័ទ្ធដោយតំបន់ភ្នំទាំងនេះ និងខ្ពង់រាបនានាដែលបង្កើតជាតំបន់ទំនាបកណ្តាល ហើយខណ្ឌចែកអាងទន្លេមេគង្គ និងអាងទន្លេសាប។ សូមបញ្ជាក់ថាទន្លេទាំងពីរនេះជួបគ្នានៅតំបន់ភាកខាងត្បូងនៃប្រទេសកម្ពុជា។ តំបន់កណ្តាលនេះបានវិវត្តន៏ពីចលនាបាក់ធ្លាក់ចុះនៃដីដែលសំបូរដោយជាតិខ្សាច់ ល្បាប់ និងថ្មក្រាវែលនាសម័យផ្លេស្តូសែន និងហូឡូសែន ។ យុគស័យនេះបង្កើតជាតំបន់នៃការសិក្សានេះព្រមជាមួយនិងតំបន់មេគង្គដែលតានៃប្រទេសវៀតណាមផង ។

ការសិក្សានេះបានគ្របដណ្តប់លើទីក្រុងភ្នំពេញទាំងមូលដែលមានទីតាំងជាប់ទន្លេមេគង្គ និងមានកំរិតកំបស់ទាបជាង ១០ម ។ ផ្ទៃថ្មរាបស្មើក៏មានដោយកន្លែង ដែលខ្លះមានរាងជាសាជីដែលបង្កពីបន្ទុះភ្នំភ្លើង ។ ផ្នែកកណ្តាលដែលជាទីតាំងទីក្រុងភ្នំពេញត្រូវចែកជាអាងទន្លេសាបភាគខាងជើង និងអាងទន្លេមេគង្គភាគខាងត្បូងនៃទីក្រុងភ្នំពេញ ។ ទន្លេមេគង្គប្រសព្វជាមួយទន្លេសាបនៅជាយក្រុងភ្នំពេញ ដែលបន្ទាប់មករួមជាទន្លេមេគង្គដែលហូរចាក់ទៅទិសខាងកើតតាមខេត្តព្រៃវែង និងព្រំប្រទល់ខេត្តស្វាយរៀង ។ ទន្លេបាសាក់ហូរទៅទិសខាងលិចតាមព្រំដែនខេត្តតាកែវ ។ នៅពេលដែលទន្លេមេគង្គជន់ហូរហៀរ នោះទឹកជំនន់ហូរត្រឡប់ចាក់ចូលបឹងទន្លេសាបវិញដែលជាអាងធម្មជាតិផ្ទុកទឹកដ៏ធំមួយ ។ លំហូរអតិបរិមានៃទន្លេមេគង្គមាន ៣៨៧១៩ ម៉ែត្រគូបក្នុងមួយវិនាទី ដោយយោងតាមកំណត់ត្រានៅស្ថានីយខេត្តកំពុងចាមនាខែ ។ តែការវាស់វែងនៅចុងលំហូរនៅ អ្នកលឿងមានតែប្រមាណ ២៤៧៨០ ម៉ែត្រគូបក្នុងមួយវិនាទី ។

### 2.1.2 ចំនួនប្រជាជន

ចំនួនប្រជាជន ដង់ស៊ីតេ និងចំនួនផ្ទះតាមខ័ណ្ឌក្នុងក្រុងភ្នំពេញ ក្នុងឆ្នាំ ២០០៣ ត្រូវបានគណនាដោយផ្អែកទៅលើ Regression Model ដោយប្រើប្រាស់ទិន្នន័យជំរឿនឆ្នាំ ១៩៩៨[១] និងទិន្នន័យប្រជាជន ដែលបានមកពីនាយកដ្ឋានផែនកា នៃសាលាក្រុងភ្នំពេញ ។

[១] វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ជំរឿនប្រជាជនកម្ពុជាទូទៅ ១៩៩៨

**Table 2-1: ចំនួនប្រជាជន ដង់ស៊ីតេប្រជាជន និងចំនួនផ្ទះ ក្នុងឆ្នាំ ២០០៣**

| ខ័ណ្ឌ (ស្រុក) | ផ្ទៃសរុប* (គ.ម²) | ផ្ទៃដី** (គ.ម²) | ចំនួនប្រជាជន | ដង់ស៊ីតេ (នាក់/ហ.ត) | ចំនួនផ្ទះ*** (ផ្ទះ/ហ.ត) |
|---|---|---|---|---|---|
| ចំការមន | ៩.៥៩ | ៩.២៦ | ២០៨.៧៥០ | ២១៧.៧ | ៣៦.៩ |
| ដូនពេញ | ៧.៣៤ | ៥.៣៩ | ១៣៧.១៨៦ | ១៨៦.៩ | ៣១.៧ |
| ៧ មករា | ២.២ | ២.១៤ | ១០៤.០១៣ | ៤៧២.៨ | ៨០.១ |
| ទួលគោក | ៧.៩៥ | ៧.៨២ | ១៧៨.៣៧៣ | ២២៤.៤ | ៣៨.០ |
| **ផ្ទៃទីប្រជុំជនសរុប** | **២៧.០៨** | **២៤.៦១** | **៦២៣.៣២២** | **២៣០.២** | **៣៩.០** |
| ដង្កោ | ១៨៧.៩១ | ១៨១.៦៩ | ១១៤.៣៣៣ | ៦.១ | ១.១ |
| មានជ័យ | ៥០.៨៦ | ៤០.១៨ | ២១០.០២៧ | ៤១.៣ | ៧.៤ |
| ឫស្សីកែវ | ១០៧.៨៨ | ៨៨.៣៣ | ២៤៦.៧៣២ | ២២.៩ | ៤.១ |
| **ផ្ទៃខ័ណ្ឌជាយក្រុងសរុប** | **៣៤៦.៦៥** | **៣១០.២** | **៥៧១.០៩២** | **១៦.៥** | **២.៩** |
| **សរុបរួម** | **៣៧៣.៧៣** | **៣៣៤.៨១** | **១.១៩៩.៤១៤** | **៣២.១** | **៥.៥** |

*: ផ្ទៃទាំងមូល

**: មិនគិតផ្ទៃទឹក

***:៥,៩នាក់ក្នុងមួយផ្ទះនៅតំបន់ទីប្រជុំជន ៥,៦នាក់នៅតំបន់ជាយក្រុង និង៥,៨នាក់ជាមធ្យម ក្នុងទីក្រុងទាំងមូលយោងតាមជំរឿនឆ្នាំ ១៩៩៨[១]

## 2.1.3 រចនាសម្ព័ន្ធទីប្រជុំជន

ទៅតាមរដ្ឋបាល ទីក្រុងត្រូវបានបែងចែកចេញជា ៧ខ័ណ្ឌ។ ក្នុងចំណោមនេះ មានខ័ណ្ឌ ៤ ដែលឋិតនៅក្នុងក្រុងដែលជាទីប្រជុំជន (ដូនពេញ ចំការមន ៧ មករា និងទួលគោក) ដែលមានផ្ទៃដីទំហំ ២៧.០៨[២]គ.ម២ និងមានប្រជាជនចំនួន ៦២៣.៣២២[៣] ។ ស្ថាប័នកំពូលៗរបស់រដ្ឋាភិបាល និងអាគាររដ្ឋបាលស្ថិតនៅក្នុងខ័ណ្ឌទាំងនេះជាពិសេសខ័ណ្ឌដូនពេញ និងខ័ណ្ឌចំការមន។ ខ័ណ្ឌដែលនៅសល់ចំនួន ៣ទៀត ឋិតនៅជាយក្រុង ឬនៅជុំវិញក្រុងដែលមានផ្ទៃ សរុប ៣៤៦.៦៥គ.ម² និងមានប្រជាជន ៥៧១.០៩២ ។ ផ្ទះលក់ទំនិញដែលស្ថិតក្នុងតំបន់មានដង់ស៊ីតេខ្ពស់ភាគច្រើនជាអាគារចាស់ៗ ៣-៦ជាន់ ដែលសាងសង់ក្នុងអាណានិគមតួយ៉ាងដូចជា "ផ្ទះលក់ទំនិញចិន" ដែលជាសណ្ឋានសំណង់តាមដងផ្លូវនិងមានជាន់ខ្ពស់ៗ ។ សំណង់ទាំងនេះអាចឱ្យទៅមកខានតាមផ្លូវត្រង់ដែលជាទូទៅភ្ជាប់ទៅជាមួយនឹងផ្លូវខ្សឿងហែម ផ្ទះដែលឋិតនៅក្នុងតំបន់មានដង់ស៊ីតេមធ្យមភាគច្រើនមាន ២-៣ជាន់ និងជាប្រភេទអាគារជាច់តែឯង ឬស្ទើរជាច់តែឯង ។

ជាប្រភេទសំណង់ក្រោយសម័យអាណានិគម។ សំណង់អាណាធិបតេយ្យមួយចំនួន ក៏ឋិតនៅក្នុងតំបន់ដែលមានដង់ស៊ីតេមធ្យមនេះដែរ ។ តំបន់ដែលមានដង់ស៊ីតេតិច ឋិតនៅជុំវិញក្រុង និងនៅជាយក្រុងហើយដែលមានប្រភេទផ្ទះច្រើន ដូចជា ផ្ទះសង់អំពីឈើ ប្រភេទផ្ទះលក់ទំនិញ ប្រភេទផ្ទះល្វែង និងស្ទើរពាក់កណ្តាលល្វែងគ្រប់ប្រភេទ ។

---

[២] យោងទៅតាម BUA ខែកកដា ឆ្នាំ២០០៣ ផ្ទៃដីប៉ាន់ស្មាននៃតំបន់ទីប្រជុំជនមាន ២៧,១៩គ.ម² និងតំបន់ជាយក្រុងមាន ៣៤៨,៣០គ.ម² គិតតាមផ្ទៃដីរាងស្វែរ

[៣] ចំនួនប្រជាជនព្យាករណ៍ក្នុងការសិក្សាដែលដឹកនាំដោយ JICA ក្នុងឆ្នាំ ២០០១ ស្តីពី "ផែនការមេគមនាគមន៍នៅតំបន់ក្រុងភ្នំពេញ"

### 2.1.4 ស្ថានភាពសេដ្ឋកិច្ច

#### a. សេដ្ឋកិច្ចជាតិ និងសេដ្ឋកិច្ចតំបន់

កំណើនផលិតផលក្នុងស្រុក GDP ក្នុងកម្ពុជា មានកំណើនជាមធ្យមប្រចាំឆ្នាំគឺ ១០,៦% ពីឆ្នាំ១៩៩៤-២០០០ ។ កំណើននេះក្នុងម្នាក់ៗមានប្រហែល ៩២០.០០០ ឬ ២៣៨ដុល្លាសហរដ្ឋ ក្នុងឆ្នាំ ២០០០ ។

យោងតាមការសិក្សាលើសេដ្ឋកិច្ច-សង្គម ឆ្នាំ ១៩៩៣-៩៤ ចំណូលជាមធ្យមសំរាប់ប្រជាជនក្នុងក្រុងភ្នំពេញ មានច្រើនជាង ៣ដងនៃចំណូលជាមធ្យមរបស់ប្រជាជនទូទៅក្នុងប្រទេសដែលមានប្រហែលជា១៦៩.០០០ ឬត្រូវជា ៦៦ដុល្លា ក្នុងមួយខែ ។ គួរចំណាំថាមានគំលាតខុសគ្នាច្រើនរវាងចំណូលដែលរកបានរវាងអ្នកនៅទីក្រុង និងនៅតាមជាយក្រុង ។

#### b. ថវិកាសាលាក្រុង និងថវិកាជាតិ

ចំណូលរដ្ឋាភិបាលកាន់កាប់មានត្រឹមតែ ៩% នៃ GDP ក្នុងឆ្នាំ ១៩៩៨ ។ រដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នកំពុងដឹកនាំកំណែទំរង់រចនាសម្ព័ន្ធនៃប្រព័ន្ធប្រមូលពន្ធដារ និងចំណូលប្រចាំឆ្នាំដើម្បីបង្កើនមូលដ្ឋានចំណូលជាតិ ។ ផែនការវិនិយោគសាធារណៈចុងក្រោយឆ្នាំ ២០០២-២០០៤ បានកំណត់គោលដៅចំណូលគឺ ១៣,៥% សំរាប់ GDP ឆ្នាំ២០០៥ ។

ម៉្យាងវិញទៀតចំណូលរបស់ក្រុងភ្នំពេញនាឆ្នាំ ២០០២ មានដល់ ២៦,៩៧២ លានរៀល (៦.៦ លានដុល្លាសហរដ្ឋ) ។ ចំណូល សំរាប់មនុស្សម្នាក់ក្នុងក្រុងត្រូវបានប៉ាន់ប្រមាណថាមានប្រហែលជា ៥.៥ ដុល្លាសហរដ្ឋ ។ ទន្ទឹមនឹងនេះ ចំណាយសរុបរបស់ ក្រុងមានប្រហែល ២៧,៨២២ លានរៀល (៦.៩ លានដុល្លាសហរដ្ឋ) ។

## 2.2 ការចុះអង្កេត

ក្រុមសិក្សាបានដឹកនាំធ្វើការស្រាវជ្រាវទៅលើចំណុចដូចមានខាងក្រោម ដើម្បីយល់ឱ្យបានច្បាស់នូវស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ននៅក្នុងតំបន់សិក្សា ។

១. ការស្រាវជ្រាវលើបរិមាណ និងសមាសភាពសំណល់ (ស្រ.ប.ស.ស)
២. ការស្រាវជ្រាវលើពេលវេលា និងសកម្មភាពរថយន្ត
៣. ការស្ទង់មតិសាធារណៈ (ស្ទ.ម.ស)
៤. ការស្រាវជ្រាវលើបរិស្ថានសង្គមនៅក្នុង និងនៅទីជុំវិញទីលានចុងក្រោយ
៥. ការស្រាវជ្រាវចំពោះកម្មករផ្នែកសំអាត
៦. ការស្រាវជ្រាវលើស្ថាប័នវេជ្ជសាស្ត្រ
៧. ការស្រាវជ្រាវអំពីរោងចក្រ
៨. ការសិក្សាអំពីទីផ្សារកែច្នៃ
៩. ការស្រាវជ្រាវលើគុណភាពទឹក
១០. ការអង្កេតអាងបង្ហូរអនាម័យ
១១. ផ្សេងៗ

## 2.2.1 ការបង្កើតសំណល់ និងបរិមាណចាក់

ដោយផ្អែកលើការសិក្សា WACS លើចំនួន ៥៦០ គ្រួសារ នារដូវប្រាំង និងវស្សានោះ គេបានទទួលនូវអត្រាបញ្ចេញសំនល់ ហើយប្រភពនៃទីកន្លែងបញ្ចេញសំណល់ក៏ត្រូវបានរកឃើញដោយការសិក្សាលើសង្កាត់ទាំង ៧៦ ។

Table 2-2: អាត្រាបង្កើតសំណល់ និងបរិមាណចាក់ ក្នុងឆ្នាំ ២០០៣

| ប្រភពចាក់ចោល | ចំនួនប្រភពចាក់ចោល | ឯកតា | អ៉ាត្រានៃការបង្កើតសំណល់ | | | បរិមាណចាក់ប្រចាំថ្ងៃ (ត/ថ) | | |
|---|---|---|---|---|---|---|---|---|
| | | | រដូវក្តៅ | រដូវភ្លៀង | មធ្យម | រដូវក្តៅ | រដូវភ្លៀង | មធ្យម |
| សំណល់តាមផ្ទះ | ១,១១៩,៤១៤ | ក្រ/ម្ន/ថ្ង | ៤៩៨ | ៤៧៦ | ៤៨៧ | ៥៩៧,៣ | ៥៧០,៩ | ៥៨៤,១ |
| សំណល់អាជីវកម្ម (ភោជនីយដ្ឋាន) | ២៧,៨០៨ | ក្រ/តុ/ថ្ង | ១.៩៤០ | ១.៣៨៧ | ១.៦៦៤ | ៥៤,០ | ៣៨,៦ | ៤៦,៣ |
| សំណល់អាជីវកម្ម (ហាងលក់ទំនិញ) | ៣៣,៥២៤ | ក្រ/ហ/ថ្ង | ៤.៥៦៦ | ៤.៤៣៧ | ៤.៥០២ | ១៥៣,១ | ១៤៨,៨ | ១៥១,០ |
| សំណល់ផ្សារ | ៥១,៧៦៦ | ក្រ/តូ/ថ្ង | ១.៧០០ | ១.៩៤៥ | ១.៨២៣ | ៨៨,០ | ១០០,៧ | ៩៤,៤ |
| សំណល់សាលារៀន | ៣៨៥,០១៣ | ក្រ/ម្ន/ថ្ង | ១៨ | ២១ | ២០ | ៦,៩ | ៨,១ | ៧,៥ |
| សំណល់សំរាមតាមផ្លូវ | ៥៦ | ក្រ/គ.ម/ថ្ង | ៤៧.២៣៥ | ៥៩.៥១០ | ៥៣.៣៧៣ | ២,៦ | ៣,៣ | ៣,០ |
| សំណល់សណ្ឋាគារ | ១៣,៣៨៥ | ក្រ/ប/ថ្ង | ១៩៩ | ២៦៣ | ២៣១ | ២,៧ | ៣,៥ | ៣,១ |
| សំណល់កន្លែងធ្វើការ | ៣៦៨ | ក្រ/ក/ថ្ង | ២.៩៤៦ | ៤.១៧៤ | ៣.៥៦០ | ១,១ | ១,៥ | ១,៣ |
| សរុប | | | | | | | | ៨៩០,៦ |

* : បរិមាណសំណល់ពីប្រភពចាក់ដូចជា សួនច្បារ ផ្ទះសត្វឃាដ មិនអាចកំណត់ប៉ាន់ស្មានបាន តាមរយៈលំហូរសំណល់ឡើយ ។

## 2.2.2 សមាសភាពសំណល់

សំណល់តាមផ្ទះដែលបញ្ចេញនាពេលបច្ចុប្បន្ន និងទិន្នន័យដែលទទួលបានពីការសិក្សារបស់ក្រុមសិក្សា JICA ត្រូវ បានបង្ហាញខាងក្រោម ។ សំណល់ច្រើនជាងគេគឺ ពីផ្ទះបាយ និងសារធាតុផ្លាស្ទិក ដែលមានប្រមាណ ៦៣.៣% និង ១៥.៥% រៀងខ្លួន។

Table 2-3 ការប្រៀបធៀបសមាសភាពសំណល់ដែលចាក់ពីផ្ទះ

| Country / Physical Composition | Unit | **Cambodia** | Malaysia | Lao | Philippines | Paraguay | Tanzania | Honduras |
|---|---|---|---|---|---|---|---|---|
| | | **Phnom Penh*** | Penang | Vientiane | Manila | Asuncion | Dar es Salaam | Tegucigalpa |
| ផ្ទះបាយ | % | **៦៣.៣០** | ៣២.៨០ | ១៦.៩០ | ៤៥.៨២ | ៣៦.៦០ | ៤២.០០ | ៤៧.២០ |
| ក្រដាស | % | **៦.៤០** | ២៥.៥០ | ២.៨០ | ១៥.៣៩ | ៦.៤០ | ៣.១០ | ១១.៥០ |
| កាត់ដេរ | % | **២.៥០** | ៣.៤០ | ១.៦០ | ៤.៣៣ | ១.៣០ | ១.២០ | ២.៨០ |
| ផ្លាស្ទិច | % | **១៥.៥០** | ១១.២០ | ៦.១០ | ១៥.៦០ | ៣.៩០ | ២.២០ | ៧.១០ |
| ស្មៅ និងឈើ | % | **៦.៨០** | ១៤.៤០ | ៣៨.២០ | ៧.៤៥ | ២២.២០ | ២៥.៣០ | ១១.៦០ |
| ស្បែក និងជ័រ | % | **០.១០** | ០.៨០ | ១.១០ | ០.៨០ | ០.៧០ | ០.៩០ | ២.២០ |
| ដែក | % | **០.៦០** | ២.៦០ | ៣.៧០ | ៥.៤៧ | ១.៣០ | ២.០០ | ១.៩០ |
| ដប និងកែវ | % | **១.២០** | ១.៤០ | ៩.៣០ | ២.៦៩ | ៣.១០ | ៣.៥០ | ៣.៥០ |
| សេរ៉ាមិច និងថ្ម | % | **១.៥០** | ០.២០ | (Included in glass) | ១.២៦ | ២.៥០ | ០.៤០ | ១២.១០ |
| ផ្សេង ៗ | % | **២.១០** | ៧.៨០ | ២០.៣០ | ១.១៩ | ២២.០០ | ១៩.៤០ | ០.១០ |
| **សរុប** | % | **១០០.០០** | ១០០.០០ | ១០០.០០ | ១០០.០០ | ១០០.០០ | ១០០.០០ | ១០០.០០ |
| ASG | kg/l | **០.២៥** | ០.១៩ | ០.១៦៨ | ០.១៩ | ០.២២ | ០.៣៩ | ០.២០ |

សំគាល់: បរិមាណសំណល់ពីប្រភពចាក់ដូចជា សួនច្បារ ផ្ទះសត្វឃាដ មិនអាចកំណត់ប៉ាន់ស្មានបាន តាមរយៈលំហូរសំណល់ឡើយ ។

## 2.2.3 សំណល់វេជ្ជសាស្ត្រ និងសំណល់ឧស្សាហកម្ម

### a. សំណល់វេជ្ជសាស្ត្រ

ក្នុងការស្រាវជ្រាវលើសំណល់វេជ្ជសាស្ត្រនេះ មានការធ្វើបទសម្ភាសន៍ជាមួយស្ថាប័នវេជ្ជសាស្ត្រចំនួន៤១កន្លែង ។ ផ្អែកតាមលទ្ធផលនៃការស្រាវជ្រាវនេះក្រុមសិក្សា បានប៉ាន់ស្មានបរិមាណសំណល់វេជ្ជសាស្ត្រដែលបានបង្កើតក្នុងក្រុងភ្នំពេញ ដូចមានបង្ហាញក្នុងតារាងខាងក្រោមនេះ ។

Table 2-4 : បរិមាណសំណល់វេជ្ជសាស្ត្រ បង្កើតក្នុងឆ្នាំ ២០០៣

| ប្រភពបង្កើត | អាត្រាបង្កើត (គ.ក្រ/គ្រែ/ថ្ងៃ) | | ចំនួនប្រភព | ចំនួនគ្រែ | អាត្រាគ្រែមានអ្នកជំងឺសំរាក | បរិមាណបង្កើត (គ.ក្រ/ថ្ងៃ) |
|---|---|---|---|---|---|---|
| សំណល់ទូទៅ | | | | | | |
| ១. មន្ទីរពេទ្យ | kg/bed/day | ៥.១៧៤ | ១៥ | ៣,២៤១ | ៣៩.៨ % | ៦,៦៧៤ |
| ២. ពហុគ្លីនិច | | ១.០៦០ | ៣៣ | ៧៧៦ | ១៩.៥ % | ១៦០ |
| ៣. គ្លីនិច | | ១.៣១៣ | ៨១៦ | ៩,០៦៧ | ២៣.០ % | ២,៧៣៨ |
| ៤. មណ្ឌលសុខភាព | | ៥.០៦៩ | ៦ | ៩២ | ៣១.៥ % | ១៤៧ |
| សរុប | | --- | ៨៧០ | ១៣១៧៦ | --- | ៩,៧១៩ |
| ១. មន្ទីរពេទ្យ | kg/person/day | ០.៣៨៥៤ | ១៥ | ១៧,៣១៨ | --- | ៦,៦៧៤ |
| ២. ពហុគ្លីនិច | | ០.០៩៣ | ៣៣ | ១,៧៣០ | --- | ១៦០ |
| ៣. គ្លីនិច | | ០.១១១ | ៨១៦ | ២៤,៦៦១ | --- | ២,៧៣៨ |
| ៤. មណ្ឌលសុខភាព | | ០.៣២៧ | ៦ | ៤៤៩ | --- | ១៤៧ |
| សរុប | | --- | ៨៧០ | ៤៤,១៥៨ | --- | ៩,៧១៩ |
| សំណល់ទូទៅ | | | | | | |
| ១. មន្ទីរពេទ្យ | kg/bed/day | ០.២៦២ | ១៥ | ៣,២៤១ | ៣៩.៨ 5 | ៣៣៨.០ |
| ២. ពហុគ្លីនិច | | ០.៣១២ | ៣៣ | ៧៧៦ | ១៩.៥ 5 | ៤៧.២ |
| ៣. គ្លីនិច | | ០.២៦៣ | ៨១៦ | ៩,០៦៧ | ២៣.០ 5 | ៥៤៨.៥ |
| ៤. មណ្ឌលសុខភាព | | ០.៩៥២ | ៦ | ៩២ | ៣១.៥ 5 | ២៧.៦ |
| សរុប | | --- | ៨៧០ | ១៣,១៧៦ | --- | ៩៦១.៣ |

### b. សំណល់ឧស្សាហកម្ម

ដើម្បីទទួលបានការយល់ដឹងពីស្ថានភាពបច្ចុប្បន្នទាក់ទងនឹងសំណល់ឧស្សាហកម្មក្នុងភ្នំពេញ ការស្រាវជ្រាវតាមរយៈការសម្ភាសន៍ជាមួយរោងចក្រចំនួន ៣២ ត្រូវបានធ្វើឡើង។ យោងតាមលទ្ធផលស្រាវជ្រាវនេះ ក្រុមសិក្សាបាន ប៉ាន់ស្មាន បរិមាណសំណល់ឧស្សាហកម្មដែលបានបង្កើត ដូចមានបង្ហាញក្នុងតារាងខាងក្រោមនេះ ។

Table 2-5: បរិមាណសំណល់ឧស្សាហកម្ម បង្កើតក្នុងឆ្នាំ ២០០៣

| ប្រភពបង្កើត | កូដ | អាត្រាបង្កើត(គ.ក្រ/ម្នាក់) | ចំនួនប្រភព | ចំនួនអ្នកធ្វើការ | បរិមាណបង្កើត(គ.ក្រ/ថ្ងៃ) |
|---|---|---|---|---|---|
| អាហារ | G01 | ៣,៨៩៣ | ២១ | ២.៤៤០ | ៩.៤៩៩ |
| វាយនភ័ណ្ឌ | G02 | ០,៤០៩ | ២៣ | ៣០.៦៨៧ | ១២.៥៥១ |
| សម្លៀកបំពាក់ | G03 | ០,២៥៤ | ១៧៩ | ១៣៧.៥៩៥ | ៣៤.៩៤៩ |
| គីមី | G04 | ០,២៩៣ | ១០ | ១.៣៥៤ | ៣៩៧ |
| អលោហៈ | G05 | ០,២៩៣ | ៤ | ៣៤៤ | ១០១ |
| សិប្បកម្មលោហៈ | G06 | ០,២៩៣ | ៩ | ៧៦១ | ២២៣ |
| ឈើ | G07 | ០,២៩៣ | ៣ | ១៤៥ | ៤២ |
| ក្រដាស | G08 | ០,៣៣៩ | ២ | ១១២ | ៣៨ |
| ផ្សេងៗ | G09 | ០,៨៥១ | ១ | ៥០៤ | ៤២៩ |
| **សរុប** | | | **២៥២** | **១៧៣.៩៤២** | **៥៨.២២៩** |

ក្នុងចំណោមសំណល់ឧស្សាហកម្មនេះ ៥១% (២៩.៦៩៧គ.ក្រ/ថ្ងៃ) ត្រូវបានប្រមូលដោយក្រុមហ៊ុនស៊ីនទ្រី និងយកទៅចាក់ចោលនៅស្ទឹងមានជ័យ។ នៅសល់ ៤៩% (២៨.៥៣២គ.ក្រ/ថ្ងៃ) ត្រូវបានប្រមូលដោយក្រុមហ៊ុនពាណិជ្ជកម្ម សាទ្បាំ និងធ្វើប្រព្រឹត្តិកម្មដោយមធ្យោបាយដែលមាននៅទីលានសំរាប់សំណល់ប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាត ដោយក្រសួងបរិស្ថាន ។

## 2.2.4 លំហូរសំណល់

**តំបន់សិក្សាទាំងមូលឆ្នាំ ២០០៣**




**តំបន់ទីប្រជុំជនក្រុងឆ្នាំ ២០០៣**




**តំបន់ជាយក្រុងឆ្នាំ ២០០៣**




Figure 2-1: លំហូរសំណល់ឆ្នាំ ២០០៣

# 2.3 ការវាយតំលៃការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន

## 2.3.1 សង្ខេបប្រព័ន្ធគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន

ប្រព័ន្ធស្ថាប័ន និងបច្ចេកទេសចំពោះការគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញបច្ចុប្បន្ន មានសង្ខេបនៅក្នុងតារាង ២-៦ និងតារាង ២-៧ ។

Table 2-6: : ប្រព័ន្ធបច្ចេកទេសបច្ចុប្បន្ន (ខែតុលា ឆ្នាំ ២០០៣)

| មុខបច្ចេកទេស | ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ១. ការបង្កើតសំណល់ (ត/ថ្ងៃ)<br>• ប្រភពបង្កើតដូចជាតាមសួនច្បារ ផ្ទះសត្តឃាដ ប៉ុន្តែស្ថានចេញពីលំហូរសំណល់មិនត្រូវបាន កំណត់ឡើយ | សំណល់ផ្ទះ ៥៨៤,១ ត/ថ្ងៃ<br>សំណល់អាជីវកម្ម (ភោជនីយដ្ឋាន) ៤៦,២ ត/ថ្ងៃ<br>សំណល់អាជីវកម្ម (ហាងលក់ទំនិញ) ១៥០,៩ ត/ថ្ងៃ<br>សំណល់ផ្សារ ៩៤,៣ ត/ថ្ងៃ<br>សំណល់សាលារៀន ៧,៧ ត/ថ្ងៃ<br>សំណល់សំរាមតាមផ្លូវ ៣,០ ត/ថ្ងៃ<br>សំណល់សណ្ឋាគារ ៣,១ ត/ថ្ងៃ<br>សំណល់កន្លែងធ្វើការ ១,៣ ត/ថ្ងៃ<br>សំណល់ផ្សេងៗ ៣៧,២ ត/ថ្ងៃ<br>**សរុប ៩២៧,៨ ត/ថ្ងៃ** |
| ២. ការចាក់ និងការទុក | • គ្មានប្រព័ន្ធសំរាប់ទុកដាក់សំរាម (ក្នុងថង់ប្លាស្ទិច)<br>• ទុកសំណល់តាមគំនរ ឬក្នុងធុងកុងទែន័រលើចិញ្ចើមផ្លូវដើរ<br>• ភោជនីយដ្ឋាន និងសណ្ឋាគារធំៗមួយចំនួន។ល។ ប្រើធុង ឬកុងទែន័រ<br>• ផ្ទះជាច្រើនដុតសំរាមតាមផ្លូវ<br>• គ្មានគោលការណ៍ ឬបទបញ្ញត្តិក្នុងការចាក់ |
| ៣. ការប្រមូល និងដឹកជញ្ជូន | |
| ៣.១ ផ្ទៃតំបន់មានសេវាប្រមូល | ៣៧៣,៧៣ គ.ម[២] |
| ៣.២ ចំនួនប្រជាជន (ឆ្នាំ ២០០៣) | |
| តំបន់រួម | ១,១៩៩,៤១៤ |
| តំបន់ទីប្រជុំជនក្រុង | ៦២៨,៣២២ |
| តំបន់ជាយក្រុង | ៥៧១,០៩២ |
| ៣.៣ អត្រាតំបន់មានសេវា ដោយយោងលើចំនួនមនុស្ស(តំលៃក្នុងរង្វង់ក្រចក ជាតំលៃដែលដកចេញការកែច្នៃនៅកន្លែងចាក់ចោល) ។ | |
| តំបន់រួម | ៧១.១% |
| តំបន់ទីប្រជុំជនក្រុង | (៧២.២%) |
| តំបន់ជាយក្រុង | ៩៥.០% (៩០.១%) |
| | ៥០.៤% (៤៥.៣%) |
| ៣.៤ ប្រព័ន្ធប្រមូលក្នុងតំបន់ NIP ដោយ រ.គ.ស.ភ | ការប្រមូលដោយរទេះរុញ (តាមចិញ្ចើមថ្នល់ ពីផ្ទះមួយទៅផ្ទះមួយដោយក្រុមជួយខ្លួនឯង) និងការប្រមូលដោយរថយន្តក្នុងតំបន់ NIP<br>ការប្រមូលសំណល់ដោយរថយន្ត Compactor truck របស់ រ.គ.ស.ភ ២ដងក្នុងមួយសប្តាហ៍ សំរាប់ទីលាន សែន សុខ |

| មុខបច្ចេកទេស | ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ក្នុងតំបន់ស៊ីនទ្រី | ការប្រមូលតាមចិញ្ចើមថ្នល់ ដោយមានស៊ីប្លេ ប្រមូលដោយរទេះរុញ/រថយន្ត |
| ៣.៥ ចំនួនដងប្រមូល | រាល់ថ្ងៃក្នុងតំបន់<br>រាល់ថ្ងៃនៅតាមបណ្តោយផ្លូវធំ ១ដង ទៅ ៣ដងក្នុងមួយសប្តាហ៍សំរាប់តំបន់ផ្សេងទៀតដោយស៊ីនទ្រី |
| ៣.៦ ឧបករណ៍ប្រមូល<br>រ.គ.ស.ភ | រថយន្ត Compactor truck (១១ តោន) ១<br>រថយន្ត Compactor truck (៤,៥ តោន) ១<br>កុងទែន័រ (២,៥ ម៣) ៦<br>កុងទែន័រ (០,៧៥ ម៣) ៥ |
| ស៊ីនទ្រី | រថយន្ត Compactor truck (KAMAZ) ៤<br>រថយន្ត Compactor truck (១១ តោន) ១៤<br>រថយន្ត Compactor truck (៩ តោន) ១<br>រថយន្ត Compactor truck (៤,៥ តោន) ១១<br>រថយន្ត Compactor truck (៣,៥ តោន) ៩<br>រថយន្ត Compactor truck (២,៥ តោន) ៨<br>រថយន្ត Dump truck (៦ តោន) ២ |
| ៣.៧ ផ្នែកទទួលបន្ទុកចំនួនបុគ្គលិក | ផ្នែកប្រតិបត្តិការណ៍សំណល់រឹង រ.គ.ស.ភ ១<br>រដ្ឋបាល ២<br>ការប្រមូលសំរាម ៧<br>ផ្នែកប្រមូលថ្លៃសំរាម **១០**<br>**សរុប** |
| ៣.៨ អ្នកម៉ៅការឯកជន<br>ចំនួនបុគ្គលិក | ស៊ីនទ្រី<br>បុគ្គលិកការិយាល័យ ៣០<br>ទំនាក់ទំនងអតិថិជន ៧៨<br>អ្នកត្រួតពិនិត្យគុណភាព ១០<br>អ្នកបើករថយន្ត ៦០<br>អ្នកប្រមូលសំរាម ២៦០<br>យន្តការី ៣៥<br>អ្នកចាត់ចែងការ និងថ្នាក់ដឹកនាំ ៤០<br>កម្មករផ្នែកបោសសំអាតពិសេស ២០ |
| ៣.៩ ថ្លៃសេវាប្រមូលសំរាមដោយ រ.គ.ស.ភ ក្នុងមួយឯកតា (ដុល្លា/តោន) | ប្រមូលដោយរទេះរុញ ១,៨៩ ដុល្លា/ត<br>ប្រមូលដោយរថយន្ត ១,៦២ ដុល្លា/ត<br>**សរុប** **៦,៧៣ ដុល្លា/ត** |
| **៤. ការបោសសំអាតផ្លូវ និងសួនច្បារ** | |
| ៤.១ ប្រព័ន្ធបោសសំអាតរបស់ រ.គ.ស.ភ | គ្មានសេវាដែលផ្តល់ដោយ រ.គ.ស.ភ ទេ ប៉ុន្តែ ស.ក.ភ.ព ដឹកនាំសំអាតនៅតាមសួនច្បារធំៗខ្លះ<br>ការសំអាតសួនច្បារត្រូវបានធ្វើដោយអង្គភាពសំអាតសួនសាធារណៈដែលចិតនៅក្រោម ស.ក.ភ.ព |
| ៤.២ ប្រព័ន្ធបោសសំអាតរបស់ ស៊ីនទ្រី | សំអាតដោយគ្រឿងយន្ត និងដោយដៃ |

| មុខបច្ចេកទេស | ស្ថានភាពបច្ចុប្បន្ន |
|---|---|
| វិធី<br>ចំនួនអ្នកបោស | រថយន្តបោសសំអាតមួយគ្រឿង<br>អ្នកបោស ៣៥០ នាក់ |
| **៥. ប្រព្រឹត្តិកម្មពាក់កណ្តាលសំរេច**<br>៥.១ ធ្វើជីកំប៉ុស្តដោយអង្គការក្រៅរដ្ឋាភិបាល | <br>អង្គការ CSARO កំពុងផលិតជីកំប៉ុស្ត ២,០ ត/ខែ នៅមណ្ឌលអភិវឌ្ឍន៍កែច្នៃសំរាម (គឺជាមូលដ្ឋាននៃការផលិតនៅ ម.អ.ក.ស)<br>COMPED កំពុងផលិតជីកំប៉ុស្ត ៦ត/ខែ (គឺជាមូលដ្ឋាននៃការផលិតនៅទីលានចាក់សំរាមស្ទឹងមានជ័យ)។ |
| **៦. ការកែច្នៃ**<br>៦.១ កន្លែងកែច្នៃឯកជន<br><br>៦.២ ញែកចំរាញ់ដោយអង្គការក្រៅរដ្ឋាភិបាល | <br>កែច្នៃសំណល់ដោយក្រុមហ៊ុនកែច្នៃឯកជនយ៉ាងសកម្ម<br>សំណល់កែច្នៃមានចំនួនប្រហែល ៤៦ ត/ថ្ងៃ<br>CSARO កំពុងញែកសំណល់ដែលអាចកែច្នៃបានក្នុងបរិមាណ ១,៥-២,០ ត/ខែ នៅ ម.អ.ក.ស |
| **៧. ការចាក់ចុងក្រោយ**<br>៧.១ ទីលានចាក់សំរាម<br>៧.២ វិធីចាក់<br>៧.៣ ការប្រើប្រាស់ដីនៅទីជុំវិញ<br>៧.៤ ចម្ងាយដឹកជញ្ជូនពីទីក្រុង<br>៧.៥ ផ្នែកទទួលបន្ទុក<br>ចំនួនបុគ្គលិក | <br>ទីលានចាក់សំរាមស្ទឹងមានជ័យ (ទ.ស្ទ.ម.ជ)<br>ចាក់ចំហរដោយគ្មានលប់ដី<br>តំបន់ដីសើម ដីខ្ចី តំបន់លំនៅដ្ឋាន<br>៥,៣ គ.ម ពីផ្សារធំថ្មី<br>ផ្នែកគ្រប់គ្រងទីលានចាក់សំរាម និងរោងជាងមេកានិច<br>រ.គ.ស.ភ<br>អ្នកគ្រប់គ្រងទីលាន ១<br>អ្នកបញ្ជាពញ្ជើង ២<br>កម្មករទីលាន ១<br>**សរុប ៤** |
| ៧.៦ គ្រឿងចក្រនៅទីលាន<br>៧.៧ ថ្លៃប្រតិបត្តិការណ៍នៅទីលានមួយឯកតា (ដុល្លា/ត) | Bulldozers (ជួល) ២<br>០,៤៣ ដុល្លា/ត |
| **៨. តំហែទាំឧបករណ៍** | រ.គស.ភ ថែរក្សារាល់គ្រឿងចក្រតាមរយៈប្រភពពីខាងក្រៅ<br>ស៊ិនទ្រី ថែរក្សាដោយរោងជាងខ្លួនឯង |
| **៩. ការគ្រប់គ្រងទឹកស្អុយ**<br>៩.១ ផ្នែកទទួលបន្ទុក<br>៩.២ ចំនួនបុគ្គលិក | <br>ផ្នែកប្រតិបត្តិការណ៍សំណល់ភក់ រ.គ.ស.ភ<br>ប្រធានប្រតិបត្តិការណ៍សំណល់ភក់ ១<br>ប្រធានផ្នែកអាជីវកម្មឯកជន ១<br>អ្នកបើកបរ ៤<br>កម្មករ ៨<br>**សរុប ១៤** |
| ៩.៣ ឧបករណ៍ប្រមូលសំណល់ | Tank truck ចំណុះ ៥,០ ម$^{៣}$ |

## Table 2-7: ប្រព័ន្ធស្ថាប័នបច្ចុប្បន្ន

| មុខបច្ចេកទេស | ស្ថានភាពបច្ចុប្បន្ន | |
|---|---|---|
| ១. ការរៀបចំ | | |
| ១.១ អង្គភាពពាក់ព័ន្ធ | រ.គ.ស.ភ | |
| ១.២ ចំនួនបុគ្គលិក | រដ្ឋបាល | ១២ |
| | ប្រតិបត្តិការណ៍សំណល់រឹង | ១០ |
| | ប្រតិបត្តិការណ៍សំណល់ភក់ | ១៤ |
| | ប្រតិបត្តិការណ៍ទីលាន និងរោងជាងមេកានិច | ៥ |
| | **សរុប** | **៤១** |
| ១.៣ ប្រព័ន្ធគ្រប់គ្រង | សាលាក្រុងចេញកិច្ចសន្យាលើការប្រមូលដល់ក្រុមហ៊ុនឯកជនលើកលែងតែតំបន់ NIP<br>រ.គ.ស.ភ មានសិទ្ធិក្នុងការពិនិត្យលើការផ្តល់សេវាប្រមូលសំរាមរបស់ស៊ិនទ្រី | |
| ២. ស្ថានភាពហិរញ្ញវត្ថុ | | |
| ២.១ សាលាក្រុងភ្នំពេញ ឆ្នាំ ២០០២ (ឯកតា : ១.០០០៛) | ចំណូល (ពិត) ២៦.៥៧២.៤៧៤ (៦.៦ លានដុល្លា)<br>ចំណាយ (ពិត) ២៧.៨២១.៩៧៤ (៦.៩ លានដុល្លា) | |
| ២.២ ថវិកាសំរាប់សេវាសំអាតឆ្នាំ ,០២ | សាលាក្រុងមិនផ្តល់ថ្លៃសេវាសំអាតទេ | |
| ២.៣ ចំណូល និងចំណាយរបស់ រ.គ.ស.ភ ឆ្នាំ ២០០២ | ចំណូល ១៥៩.១៣៩,៥០ ដុល្លាសហរដ្ឋ<br>ចំណាយ ១៥៦.៤០៧,៨៩ ដុល្លាសហរដ្ឋ | |
| ២.៤ ប្រព័ន្ធប្រមូលថ្លៃសំរាម | | |
| a. សាធារណៈ (រ.គ.ស.ភ) | ប្រមូលផ្ទាល់ពីតំបន់ NIP | |
| b. ឯកជន | ភ្ជាប់វិក័យប័ត្រថ្លៃប្រមូលសំរាម | |
| ២.៥ អត្រាថ្លៃប្រមូលសំរាម | | |
| a. សាធារណៈ (រ.គ.ស.ភ) | ឆ្នាំ ២០០២ | ៦០% (តាមផ្ទះ) |
| b. ឯកជន | ឯកជន | ៦០% (តាមផ្ទះ)<br>១៥% (អាជីវកម្ម) |
| ២.៦ ពន្ធ | ពន្ធត្រូវបានដាក់ដោយសាលាក្រុង<br>ពន្ធថ្មីចាប់ផ្តើមអនុវត្តពីចុងខែតុលា ឆ្នាំ ២០០៣ | |
| ២.៧ ចំណូលពីថ្លៃប្រមូលសំរាម | | |
| a. សាធារណៈ (រ.គ.ស.ភ) | តំបន់ NIP ឆ្នាំ ២០០២ | ,៣០.៧១៧,០៨ ដុល្លា |
| b. ឯកជន | គ្មានទិន្នន័យ | |
| ៣. មូលដ្ឋានច្បាប់ | លក្ខន្តិកៈរបស់ រ.គ.ស.ភ ត្រូវបានឯកភាពពីសាលាក្រុងកាលពីខែកញ្ញា ឆ្នាំ ២០០៣ ប៉ុន្តែមិនទាន់មានសុពលភាពស្របច្បាប់ដោយរដ្ឋាភិបាលនៅឡើយ | |

| មុខបច្ចេកទេស | ស្ថានភាពបច្ចុប្បន្ន |
|---|---|
| ៤. សហការសាធារណ: | មានជាកម្មវិធីអប់រំសាធារណ:តិចតួច និងកិច្ចសហការ |

សំគាល់ : ទិន្នន័យពី ក្រុមហ៊ុន ស៊ិនទ្រី

## 2.3.2 ការវាយតំលៃលើការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន

ការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ននៅក្រុងភ្នំពេញត្រូវបានធ្វើការវាយតម្លៃដែលមានបង្ហាញក្នុងតារាងខាងក្រោម ។

Table 2-8: ការវាយតម្លៃស្ថានភាពគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញបច្ចុប្បន្ន

| មុខបច្ចេកទេស | | ខណ្ឌក្នុងក្រុង (ខណ្ឌទាំង ៤) | ខណ្ឌជាយក្រុង (ខណ្ឌទាំង ៣) |
|---|---|---|---|
| ប្រព័ន្ធបច្ចេកទេស | ១. ការបង្កើតសំណល់ | ● ការបង្កើតសំណល់តាមផ្ទះក្នុងមួយឯកតាគឺ ៤៨៧ក្រ/ម្ន/ថ្ងៃ<br>● សមាមាត្រនៃសំណល់ចង្ក្រានបាយមានកំរិតខ្ពស់គឺ ៦៣,៣% ។ សមាមាត្រនៃសំណល់ដែលអាចកែច្នៃបាន ដូច ជា លោហ: ក្រដាស និងជប គឺរួមទាំងអស់ ២៣,៧% ។ ដោយឡែកសមាមាត្រសំណល់ប្លាស្ទិចគឺ ១៥,៥% ដែលមានកំរិតខ្ពស់ ។ ជបជ័រកាន់តែមានអ្នកនិយមច្រើន ឯការប្រើប្រាស់ថង់ប្លាស្ទិចកាន់តែកើនឡើងច្រើនដែរ អត្រានៃតំរូវការប្រើប្រាស់នេះមានខ្ពស់ដូចជានៅតាមបណ្តាប្រទេសអភិវឌ្ឍន៍ដែរ ។ | |
| | ២. ការចាក់សំណល់តាមប្រភព | ● ២,៥% នៃសំណល់ដែលបានបង្កើតត្រូវបានចាក់ចោលដោយខ្លួនឯង ៦២,៥% ទៀតចាក់ខុសច្បាប់ដោយអ្នកបង្កើត ។ ផលធៀបនៃតួលេខទាំងនេះមានកំរិតទាប ។<br>● ហេតុផលដែលតួលេខទាំងនេះទាបគឺថា ប្រហែល ៩០% នៃសំណល់ដែលបង្កើតក្នុងតំបន់គ្មានសេវាត្រូវ បានប្រជាជនយកទៅចោលក្នុងតំបន់មានសេវា ។<br>● ហេតុផលផ្សេងទៀតនោះគឺថាតំបន់នេះជាតំបន់ដែលមានចំនួនប្រជាជនច្រើនជ្រុល (ដង់ស៊ីតេ ២៣០,២ ន/ហ.ត) និងមានដីទំនេរ ឬសួនច្បារតិចតួច ដូច្នេះការចាក់ខ្លួនឯង ឬចាក់ខុសច្បាប់ពុំសូវឃើញមានទេ ផ្អែកតាមការសិក្សាអំពីលំហូរសំណល់ ។ | ● ជាង ៣៤,៥% នៃសំណល់ដែលបានបង្កើតត្រូវបានចាក់ចោលដោយអ្នកបង្កើត ។ ការចាក់ខុសច្បាប់ មាន ១៥,១% គឺមាន ៦ដងច្រើនជាងនៅក្នុងតំបន់ទីប្រជុំជនក្នុងក្រុង ។<br>● ហេតុផលចំបងចំពោះអត្រាការចាក់ដោយខ្លួនឯងនិងដោយខុសច្បាប់នេះគឺដោយសារសេវាប្រមូលមានតិចតួចក្នុងតំបន់នេះ ។ ម្យ៉ាងទៀតដោយសារថា ជាតំបន់ដែលមានប្រជាជនតិចតួចរស់នៅ (ដង់ស៊ីតេ ១៦,៥ ន/ហ.ត) និងមានដីទំនេរ និងផ្ទះមានសួនច្បារច្រើន ដែលផ្តល់លទ្ធភាពដល់ការចាក់ដោយខ្លួនឯង និងដោយខុសច្បាប់ ។ |
| | ៣. ការទុក និងការចាក់ | ● ថង់ប្លាស្ទិចត្រូវបានប្រើប្រាស់ទូលំទូលាយក្នុងការទុកសំណល់មុនពេលយកទៅចាក់ ។<br>● ស្របពេលដែលគ្មានបទបញ្ញត្តិស្តីពីការចាក់ សំរាមតែងកើតមាននៅទីក្រុងជានិច្ចដោយសារថាប្រជាជនតែងចាក់សំរាមក្រោយពេលសេវាប្រមូលបានធ្វើ ។<br>● អ្នកលក់ដូរតាមចិញ្ចើមថ្នល់ និងការចតរថយន្តលើចិញ្ចើមផ្លូវដើរ រំខានដល់ការងារសំអាត ហើយតែងមានការពង្រាយដោយជនជំពូកនេះថែមទៀត ។<br>● មានគំនរសំរាមតាមចិញ្ចើមផ្លូវដើរ និងផ្លូវបើកបរបង្កជាភាពគគ្រិច ទោះជានៅកណ្តាលក្រុងក៏ដោយបំផ្លាញសោភ័ណភាពក្រុង និងសុខភាពសាធារណ:។<br>● សង្កាត់បានរាយការណ៍ថាមានគំនរសំរាមចំនួន ៥៧ គំនរនៅតាមខណ្ឌទាំង៤ ក្នុងក្រុង ។ | ● វិធីទុក និងចាក់សំណល់មានលក្ខណ:ខុសប្លែកៗគ្នាពីកន្លែងមួយទៅកន្លែងមួយទៀត ។<br>● មានគំនរសំរាមដែលបង្កើតជាភាពគគ្រិចនៅតាមតំបន់ទីប្រជុំជន និងតំបន់មនុស្សច្រើន បំផ្លាញសោភ័ណភាពក្រុង និងសុខភាពសាធារណ: ។<br>● សង្កាត់បានរាយការណ៍ថាមានគំនរសំរាមចំនួន ៦ គំនរនៅតាមខណ្ឌទាំង ៣ ក្នុងជាយក្រុង ។<br>● បញ្ហាពង្រាយសំរាមមិនសូវជាចោទធ្ងន់ប៉ុន្មានទេនៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប ។<br>● បញ្ហាអនាម័យ និងសោភ័ណភាពនៃការពង្រាយសំណល់នៅតាមទីដីទំនេរ គឺជាបញ្ហាធ្ងន់ធ្ងរជាពិសេសនៅតាមទីកន្លែងដែលប្រជាជន ត្រូវមកតាំងទីលំនៅ ។ |

| មុខបច្ចេកទេស | ខ័ណ្ឌក្នុងក្រុង (ខ័ណ្ឌទាំង ៤) | ខ័ណ្ឌជាយក្រុង (ខ័ណ្ឌទាំង ៣) |
|---|---|---|
| | ● មានសណ្ឋាគារ ភោជនីយដ្ឋាន និងហាងទំនិញធំខ្លះ ប្រើប្រាស់ធុង ឬកុងទែន័រក្នុងការទុកសំណល់ក្នុងកន្លែងរបស់ខ្លួន ។ | |
| **៤. ការប្រមូល និងការដឹកជញ្ជូន** | ● អត្រាប្រមូលសំណល់ក្នុងករណីដែលចំនួនប្រជាជនត្រូវបានប៉ាន់ស្មានថាមានចំនួន ៩៥,០% តាមរយៈការបូកបន្ថែមនូវអត្រាកែច្នៃនៅតាមប្រភព (៤,៩%) និងអត្រាចាក់ចំពោះសេវាប្រមូលគឺ (៩០,១%) ។ | ● អត្រាប្រមូលសំណល់ ករណីដែលចំនួនប្រជាជនត្រូវបានប៉ាន់ស្មានថាមាន ៥០,៤% តាមរយៈការបូកបន្ថែមនូវអត្រាកែច្នៃនៅតាមប្រភព (៥,១%) និងអត្រាចាក់ចំពោះសេវាប្រមូលគឺ (៤៥,៣%)។ |
| | ● ដោយសារថារថយន្តប្រមូលសំរាមមានស្ថានភាពចាស់ (ប្រើពី ៨-២៥ ឆ្នាំ) និងខូចជាច្រើនផង សេវាប្រមូលមិនអាចដំណើរការតាមកម្មវិធីឡើយ ។ ជាលទ្ធផល គឺការចាក់នោះមិនត្រូវបានប្រមូលឡើយ ។<br>● ការចូកគំនរសំរាមនៅលើចិញ្ចើមផ្លូវដើរ និងតាមផ្លូវទាមទារឱ្យមានកម្លាំងពលកម្មដើម្បីកាត់បន្ថយទំហំនៃការប្រមូលនេះ ។<br>● សំរាមដែលចាក់គរនៅតាមទីទំនេរដែលរថយន្តមិនអាចចូលប្រមូលដល់ ត្រូវខានទុកចោលដែលបង្កឱ្យ ប៉ះពាល់ដល់បរិស្ថានជុំវិញ ។<br>● ប្រជាជនភាគច្រើនក្នុងខ័ណ្ឌទាំង ៤ នៅក្នុងក្រុងពេញចិត្តចំពោះការផ្តល់សេវាប្រមូលនេះ ។ ការប្រមូលមាននៅគ្រប់ទីកន្លែង តួយ៉ាង ការប្រមូលសំរាមចេញពីបរិស្ថានរស់ នៅជាទូទៅត្រូវខានសំរេចតាមគោលបំណង ។<br>● ក្នុងផ្នែកខ្លះនៃតំបន់ ឧទាហរណ៍ តំបន់ NIP អតីតអ្នករើសសំរាមត្រូវបានចងក្រងជាក្រុមជួយខ្លួនឯង ហើយដែលក្រុមនេះជាអ្នកផ្តល់សេវាប្រមូលតាមរយៈការអូសរទេះ ។ វិធីនេះមានប្រសិទ្ធិភាពណាស់ក្នុងការពង្រីកសេវាប្រមូលទៅដល់ តំបន់ដែលរថយន្តមិនអាចចូលទៅដល់ដោយងាយ ។<br>● តំបន់ NIP ជាតំបន់តែមួយគត់ដែល រ.គ.ស.ភ គិតគូដល់ក្នុងការផ្តល់សេវាប្រមូល ។ ទោះបីជា រ.ក.ស.ភ មានឡាន Compacter truck និង skip loader truck ប៉ុន្តែការប្រមូលបានតែ ១៩ត/ថ្ងៃ ប៉ុណ្ណោះ ។<br>● ប្រព័ន្ធស្តារធនធានសំណល់ឡើងវិញដោយមិនចាំបាច់តាមបច្ចេកទេសនៅតាមប្រភពបង្កើត និងចំណុចចាក់សំណល់ មានដំណើរការប្រកបដោយប្រសិទ្ធិភាព ។ នៅក្នុងទិដ្ឋភាពនៃការកាត់បន្ថយ ការកែច្នៃ និងការសំអាត ការញែកប្រភពសំណល់គឺជាចំណុចប្រសើរបំផុត ។ | ● ដោយសារថារថយន្តប្រមូលសំរាមមានស្ថានភាពចាស់ (ប្រើពី ៨-២៥ ឆ្នាំ) និងខូចជាច្រើនផង សេវាប្រមូលមិនអាចដំណើរការតាមចន្លោះពេលកំណត់ បានឡើយ ។ ជាលទ្ធផល ការចាក់ដោយប្រជាជននេះត្រូវទុកចោលមិនបានប្រមូលឡើយ ។<br>● ការចាក់ដោយខ្លួនឯង និងការចាក់ដោយគ្មានរបៀបមានកំរិតខ្ពស់នៅតាមតំបន់ដែលមានប្រជាជនតិច។ ទំបន់ដែលមានប្រជាជនច្រើន ពុំមានសេវាកម្មប្រសើរទេ។ ដូច្នេះ គេគួរផ្តល់អទិភាពដល់តំបន់ទាំងនោះ ។<br>● ក្នុងតំបន់ខ្លះ សេវាប្រមូលជាចំបងត្រូវបានសាកល្បងធ្វើតាមដូចក្នុងតំបន់ NIP ដែរ ប៉ុន្តែសេវាក្នុងតំបន់ទាំងនោះ រថយន្តដឹកមិនអាចចេញចូលដល់បាន ។ ដោយសារផ្នែកភាគច្រើននៃតំបន់ក្រីក្រ និងពុំមានសេវាប្រមូល គឺជាតំបន់ដែលពិបាកចេញចូល វិធីប្រើនៅក្នុងតំបន់ គួរតែជួលសេវាប្រមូលបន្ថែមដើម្បីពង្រីកទៀត ។<br>● ពុំមានតំបន់ដែលផ្តល់សេវាដោយ រ.គ.ស.ភ ទេ ។ សេវាត្រូវបានផ្តល់ឱ្យតែតាមក្រុមហ៊ុនឯកជនដែលធ្វើឡើងផ្អែកតាមគោលការណ៍សេដ្ឋកិច្ច ។ ដោយសារតែលក្ខណៈនៃតំបន់ ប្រសិទ្ធិភាពនៃសេវាប្រមូលមិនអាចមានកំរិតខ្ពស់ឡើយ ហើយការផ្តល់សេវាតាមរយៈស្ថាប័នសាធារណៈចាំឱាច់ត្រូវពិចារណា ។<br>● មានប្រព័ន្ធស្តារធនធានសំណល់ឡើងវិញដោយមិនចាំបាច់ធ្វើតាមបច្ចេកទេសនៅតាមប្រភពបង្កើត និងនៅតាមចំណុចចាក់សំណល់ដោយសកម្ម ។<br>● ពុំមានប្រព័ន្ធផ្ទេរសំណល់ឡើយ ។ រថយន្តប្រមូលសំរាមត្រូវដឹកផ្ទាល់ទៅទីលាន ស្ទ.ម.ជ តែម្តង ។ ដោយសារថាចម្ងាយដឹកជញ្ជូនពីតំបន់និមួយៗទៅទីលាន មានលើសពី ២០គ.ម ដូច្នេះការបង្កើតប្រព័ន្ធចំណុចផ្ទេរសំណល់គឺជាការចាំបាច់ ។ |

<table>
<tr><th colspan="2">មុខបច្ចេកទេស</th><th>ខណ្ឌក្នុងក្រុង (ខណ្ឌទាំង ៤)</th><th>ខណ្ឌជាយក្រុង (ខណ្ឌទាំង ៣)</th></tr>
<tr><td></td><td></td><td>● លើកលែងតែតំបន់ NIP ចេញ ប្រព័ន្ធផ្ទេរសំណល់គឺពុំត្រូវបានប្រើប្រាស់ឡើយ ។ រថយន្តប្រមូលសំរាមត្រូវដឹកផ្ទាល់ទៅទីលាន ស្ទ.ម.ជ តែម្តង ។ ទីលាននេះមានចម្ងាយ ១០គ.ម ពីទីក្រុង វាហាក់ដូចជាមិនចាំបាច់ត្រូវការទីសំរាប់ធ្វើការផ្ទេរសំរាមឡើយ ។</td><td>●</td></tr>
<tr><td></td><td>៥. ការសំអាតផ្លូវ និងសួនច្បារ</td><td>● សេវាបោសតាមផ្លូវត្រូវបានផ្តល់ដោយក្រុមហ៊ុនស៊ីនទ្រី ដោយមានតម្លៃប្រមូលជាប្រភពហិរញ្ញវត្ថុ ។<br>● សេវាសំអាតធ្វើតែតាមផ្លូវ និងសួនច្បារសំខាន់ៗក្នុងក្រុងប៉ុណ្ណោះដែលជួយដល់សោភ័ណភាពទីក្រុង ។<br>● គ្រឿងចក្រត្រូវបានប្រើប្រាស់សំរាប់សេវាសំអាតក្នុងតំបន់មានកំណត់ ។ ការសំអាតដោយដៃគឺជាការអនុវត្តន៍សំខាន់ក្នុងការជួយបង្កើតការងារ ។</td><td>● សេវាបោសផ្លូវត្រូវបានធ្វើតែតាមផ្លូវទៅកាន់ចំណតអាកាសយានប៉ុណ្ណោះដោយក្រុមហ៊ុនស៊ិនទ្រី ដោយមានតម្លៃប្រមូលជាប្រភពហិរញ្ញវត្ថុ ។<br>● ការសំអាតដោយដៃគឺជាការអនុវត្តន៍សំខាន់ក្នុងការជួយបង្កើតការងារ ។</td></tr>
<tr><td></td><td></td><td colspan="2">● ការងារសំអាតតាមសួនសាធារណៈធ្វើឡើងដោយ ស.ក.ភ.ព ផ្នែកសួនច្បារ<br>● ក្រុមហ៊ុនស៊ិនទ្រីដឹកសំរាមផ្ទាល់ទៅកាន់ទីលានចាក់ស្ទឹងមានជ័យ ។</td></tr>
<tr><td></td><td>៦. ប្រព្រឹត្តិកម្ម ពាក់កណ្តាលសំរេច</td><td>● មធ្យោបាយធ្វើជីកំប៉ុស្តមួយ (សមត្ថភាពផលិតកម្ម ប្រហែល ២,០ត/ថ្ងៃ) ត្រូវបានប្រតិបត្តិការណ៍ដោយអង្គការ NGO និង CSARO ។ គុណភាពផលិតផលជីកំប៉ុស្តមានកំរិតខ្ពស់ដោយសារថាការផលិតមានការសំរិតសំរាំង ប៉ុន្តែទីផ្សារវាមានភាពមិនចិតថេរ ។</td><td>● មានរោងធ្វើជីកំប៉ុស្តមួយដឹកនាំធ្វើដោយ NGO និង CSARO នៅទីលាន ស្ទ.ម.ជ (តាមរបាយការណ៍សមត្ថភាពផលិតមានប្រហែល ៦,០ត/ថ្ងៃ ធ្វើដោយ NGO ដែលហាក់ដូចជាច្រើនជ្រុល)។ សំណល់បានពីទីផ្សារ ដូច្នេះគុណភាពកំប៉ុស្តមានខ្ពស់ ប៉ុន្តែទីផ្សារវាមិនចិតថេរ ។ យោងតាមការស្ទង់មតិសាធារណៈ ការធ្វើជីកំប៉ុស្តត្រូវបានធ្វើនៅតាមផ្ទះមួយចំនួន ។</td></tr>
<tr><td></td><td></td><td colspan="2">● ការផ្សព្វផ្សាយពីជីកំប៉ុស្តគឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធិភាពក្នុងការបង្កើនអត្រាកែច្នៃសំណល់ ។ ការវាយតម្លៃលទ្ធភាពគំរោង ទាមទារឱ្យមានការស្រាវជ្រាវទីផ្សារ ដូចជាការសិក្សាអំពីតម្លៃប្រកួតប្រជែងផលិតផល ដូចជាជីសរីរាង្គ ។ ចាំខាច់ត្រូវមានការផ្សព្វផ្សាយចំណេះដឹងទៅដល់កសិករទៅដល់ប្រសិទ្ធិភាពកែលំអដីតាមរយៈការប្រើប្រាស់ជីកំប៉ុស្ត និងធ្វើការលើកទឹកចិត្តដល់តំរូវការប្រើ ។<br>● មន្ទីរពេទ្យធំៗមានឡដុតតូចៗសំរាប់រំលាយសំណល់ឆ្លង ប៉ុន្តែពុំបានអនុវត្តឱ្យពេញសមត្ថភាពទេ ដោយសារតែបញ្ហាបច្ចេកទេស និងហិរញ្ញវត្ថុ ។</td></tr>
<tr><td></td><td>៧. ការកែច្នៃ</td><td colspan="2">● អត្រាកែច្នៃរបស់ក្រុងមាន ៩,៣% (៨៥,៨ត/ថ្ងៃ) នៃបរិមាណបង្កើតសរុប ដែលអាចប្រៀបធៀបជាមួយជប៉ុន (១៣,១% ក្នុងឆ្នាំ ១៩៩៩) ។ ប៉ុន្តែ ប្រព័ន្ធកែច្នៃនៅក្នុងប្រទេសទាំង ២គឺ ខុសគ្នាខ្លាំង ។ ក្នុងជប៉ុន ការកែច្នៃធ្វើដោយក្រុមសហគមន៍ (៥,១%) តាមរយៈឧបករណ៍កែច្នៃ និងគ្រឿងចក្រ ប៉ុន្តែក្នុងកម្ពុជា ការកែច្នៃធ្វើឡើងដោយកម្លាំងពលកម្មមានតម្លៃថោក មិនប្រើបច្ចេកទេស ។<br>● អង្គការ NGO ដូចជា CSARO ធ្វើការកែច្នៃទោះបីជាក្នុងកំរិតមានកំណត់ក៏ដោយ ។ ប្រព័ន្ធកែច្នៃតាមកន្លែងធ្វើនិមួយៗមានការអភិវឌ្ឍន៍បានល្អ ។<br>● ការកែច្នៃក្រៅផ្លូវការដោយអ្នករើសសំរាម តាមប្រភព និងតាមចំណុចចាក់សំរាម មានលក្ខណៈសកម្ម ។ ការកែច្នៃរបស់ពួកគាត់តាមការប៉ាន់ស្មានមានចំនួនដល់ ៦៧,៥ត/ថ្ងៃ ឬ ៧,៣% នៃបរិមាណបង្កើតក្នុងក្រុងសរុប ។<br>● អ្នកប្រើប្រាស់សំណល់ចុងក្រោយមានប្លែកៗពីគ្នា ប៉ុន្តែទំហំជំនួញរបស់ពួកគាត់មានកំរិតតូច ។ ភាគច្រើននៃសំណល់ដែលអាចស្តារឡើងវិញទាំងនេះត្រូវបានដឹកចេញទៅប្រទេស វៀតណាម និងថៃ ។<br>● នៅទីលានចាក់សំរាមស្ទឹងមានជ័យ មានអ្នករើសសំរាមជាង ៥០០ នាក់ ធ្វើការពាក់ព័ន្ធនឹងការស្តារធនធានប្រើប្រាស់ឡើងវិញ ។</td></tr>
</table>

| មុខបច្ចេកទេស | | ខ័ណ្ឌក្នុងក្រុង (ខ័ណ្ឌទាំង ៤) | ខ័ណ្ឌជាយក្រុង (ខ័ណ្ឌទាំង ៣) |
|---|---|---|---|
| | ៨. ការចាក់ចុងក្រោយ | ● ទីលានចាក់សំរាមស្ទឹងមានជ័យ គឺជាទីលានតែមួយគត់ក្នុងក្រុងភ្នំពេញ ។ ប្រតិបត្តិការណ៍មិនអចិន្ត្រៃយ៍លើទីលាននេះបានបន្តអស់រយៈពេល ៣៨ឆ្នាំ មកហើយគិតតាំងពីឆ្នាំ ១៩៦៥ មក ។ សាលាក្រុងមានផ្ទៃដីតូចនេះ ត្រឹមតែ ៦,៨ ហ.ត ប៉ុណ្ណោះ សំរាប់ទីក្រុងដែលមានប្រជាជនជាង ១លាននាក់ ហើយដែលសំរាមយកទៅចាក់ទីនេះ បានហូរហៀររហូតដល់ផ្ទៃដីឯកជនដែលនៅជុំវិញទីនោះ ។ តាំងពីការចាក់នៅទីនេះមានកំពស់ ៥ម ការលំបាកក្នុងការដែលឱ្យរថយន្តចេញចូលទៅចាក់នៅកន្លែងនោះកាន់តែយ៉ាប់ទៅៗ ។ ការចេញចូលទៅកាន់ទីលានតែងជួបការលំបាកដែរ ជាពិសេសនៅរដូវភ្លៀង ហើយដែលជួនកាលត្រូវបន្ថយនូវការងារចាក់នេះវិញ ។ ការបង្កើនការកែលំអផ្លូវចេញចូល និងសន្តិសុខនៅទីលាន ជាបញ្ហាបន្ទាន់ដែលត្រូវពិចារណា ។<br>● ទីលានជាប្រភេទទីលានចាក់ចំហរគ្មានបច្ចេកទេស បង្កជាហេតុប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរទៅលើបរិស្ថានជុំវិញ ។ | |
| | | ការបំពុលខ្យល់ដែលបណ្តាលមកពីផ្សែង ភ្លើងឆេះទីលាន បង្កជាបញ្ហាធ្ងន់ធ្ងរមិនត្រឹមតែចំពោះបរិវេណជុំវិញទីលានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសាយភាយមួយផ្នែកលើទីក្រុងទាំងមូលទៀតផង ។ ដូច្នេះការទប់ស្កាត់ភើងឆេះនេះក៏ជាបញ្ហាបន្ទាន់មួយដែលត្រូវគិតគូផងដែរ ។<br>● ការមកដល់នៃរថយន្តដឹកសំរាមនៅទីលានមិនត្រូវបានធ្វើការត្រួតពិនិត្យឡើយ ។ គឺមិនត្រូវបានដឹងនូវប្រភេទសំណល់ដែលបានដឹកមក និងថាតើត្រូវចាក់នៅផ្នែកណានៃទីលាន ។ សំណល់ឆ្លងត្រូវបានចាក់ដោយពុំមានការបែងចែកឱ្យខានច្បាស់ពីសំណល់ក្រុងធម្មតាឡើយ ។<br>● បញ្ហាចំបងនៅទីនេះគឺថាអាយុកាលនៃសមត្ថភាពផ្ទុករបស់ទីលានវាស្ទើរតែអស់ទៅហើយ ហើយម៉្យាងទៀតការតាំងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋកាន់តែខិតមកជិតទីលាននេះ ដែលមានចម្ងាយមិនដល់ ១០០ម ផង ដោយសារតែកំណើនទីប្រជុំជន ។ ហេតុដូច្នេះការសាងសង់ទីលានថ្មីជាតំរូវការបន្ទាន់តាមដែលអាចធ្វើបាន ហើយដែលទីលានចាស់ត្រូវបិទវិញ ។<br>● មានអ្នករើសសំរាមជាង ៥០០ នាក់កំពុងធ្វើការនៅទីលានដោយគ្មានបទបញ្ញត្តិត្រឹមត្រូវ ។ សកម្មភាពស្តារធនធាននៅទីនេះឡើងវិញជាទធ្វើឱ្យរាំងស្ទះដល់សកម្មភាពប្រតិបត្តិការណ៍នៅទីលាន ហើយដែលធ្វើឱ្យជីវិតរបស់ពួកគាត់អាចជួបនឹងហានីភ័យ ។ ដូចនេះ វាទាមទារឱ្យមានការបំបែកតំបន់ការងាររវាងអ្នករើសសំរាម និងរវាងតំបន់ការងារគ្រឿងចក្រធុនធ្ងន់ និងរថយន្តប្រមូលសំរាម ដើម្បីធានាដល់ប្រសិទ្ធិភាពប្រតិបត្តិការណ៍ទីលាន និងសុវត្ថិភាពរបស់អ្នកស្តារធនធានសំណល់ទីនេះ ។<br>● រាល់ឧបករណ៍ដែលប្រតិបត្តិការណ៍នៅទីលានសុទ្ធតែជារបស់ជួល ។ តាំងពីឧបករណ៍នៅទីលាន និងប្រេងឥន្ធនៈត្រូវខានកាត់បន្ថយ ប្រតិបត្តិការណ៍នៅទីលានមិនត្រូវបានធ្វើឱ្យពេញគ្រប់គ្រាន់ទេ ដោយសារតែបញ្ហាហិរញ្ញវត្ថុ ។ | |
| | ៩. ប្រតិបត្តិការណ៍ និងតំហែទាំ គ្រឿងចក្រ | ● គ្រឿងចក្ររបស់ក្រុមហ៊ុនស៊ិនទ្រី សំរាប់ការប្រមូល ដឹកជញ្ជូន និងការសំអាតផ្លូវ ដែលត្រូវខានប្រើប្រាស់សំរាប់រយៈពេលពី ៨-២៥ឆ្នាំ ជាញឹកញយតែងមានការខូច ។ ទោះបីជារោងជាងរបស់ស៊ិនទ្រី នៅក្នុង បឹងកក់ ១ និងទួលគោក មានឧបករណ៍ជួសជុលមិនគ្រប់គ្រាន់ ក៏ស៊ិនទ្រី អាចរក្សាគ្រឿងចក្រទាំងនោះឱ្យថិតក្នុងលក្ខខណ្ឌការងារខានដែរ ។ ប៉ុន្តែ ស៊ិនទ្រី មិនអាចធ្វើទៅតាមកម្មវិធីប្រមូលដែលបានកំណត់រួចនោះទេ ។<br>● រ.គ.ស.ភ ពុំមានធនធានមនុស្ស ឧបករណ៍ ឬសម្ភារៈ ដើម្បីប្រតិបត្តិការណ៍ និងថែរក្សាគ្រឿងចក្ររបស់ខ្លួននោះទេ ។ នៅពេលដែលមានគ្រឿងចក្រខូច ការងារជួសជុលត្រូវប្រគល់ទៅឱ្យរោងជាងឯកជនជាអ្នកធ្វើ ។<br>● រាល់គ្រឿងចក្រនៅទីលានសុទ្ធតែជារបស់ជួល ហើយដែលក្រុមហ៊ុនឯកជនខានបង្កើតរោងជាងតូចមួយនៅទីលានសំរាប់ធ្វើការងារជួសជុល ។ | |
| | ១០. ការគ្រប់គ្រងទឹកស្អុយ | ● ទឹកស្អុយដែលបានបង្កើតនៅក្នុងក្រុងត្រូវបានប្រមូលដោយរថយន្តរបស់ រ.គ.ស.ភ ចំនួន ៣គ្រឿង និងរបស់ក្រុមហ៊ុនឯកជនចំនួន ១១គ្រឿងទៀត ។<br>● យោងតាមកំណត់ត្រាឆ្នាំ ២០០៣ មានបរិមាណទឹកស្អុយចំនួន ៥,៨ម$^{៣}$/ថ្ងៃ ត្រូវបានដឹកយកទៅចាក់ចោលនៅទីលានស្ទឹងមានជ័យ ជាមធ្យម ។ | |

| មុខបច្ចេកទេស | | ខ័ណ្ឌក្នុងក្រុង (ខ័ណ្ឌទាំង ៤) | ខ័ណ្ឌជាយក្រុង (ខ័ណ្ឌទាំង ៣) |
|---|---|---|---|
| | | ● តាមការត្រួតពិនិត្យតួលេខទាំងនេះ គឺជាការគិតដែលមានបរិមាណច្រើនខ្លាំងពេកចំពោះការប្រមូលទឹកស្អុយដោយក្រុមហ៊ុនឯកជនដែលត្រូវបានយកទៅចាក់នៅក្រៅទីលានស្ទឹងមានជ័យ ។ គួរតែមានការណែនាំឱ្យបានខ្លាំក្លាលើការចាក់ឱ្យបានត្រឹមត្រូវ ។<br>ការបង្កើតប្រព័ន្ធចាក់ទឹកស្អុយទាមទារឱ្យមានការយល់ដឹងឱ្យបានសមស្របត្រឹមត្រូវពី ស្ថានភាពជាក់ស្តែង តាមរយៈការសិក្សាលើបរិមាណអាងទឹកស្អុយ ចំនួនដងនៃការស្តារបញ្ចេញទឹកស្អុយពីអាងនេះ និងលើទិដ្ឋភាពផ្សេងៗទៀត ។<br>● ទឹកស្អុយនេះត្រូវបានចាក់ទៅក្នុងអាងសំណល់ភក់ដែលបានសាងសង់នៅផ្នែកខាងលើនៃទីលានស្ទឹងមានជ័យ ។ ដោយសារថាវិធីនេះមានលក្ខណៈសាមញ្ញ និងអស់តម្លៃទាប ជំរើសនេះត្រូវបន្តធ្វើតទៅទៀត ។ | |
| ប្រព័ន្ធស្ថាប័ន | ១១. ប្រព័ន្ធច្បាប់ | មានអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹងដែលបានបង្កើតឡើងក្នុងខែមេសា ឆ្នាំ ១៩៩៩ និងដែលជាមូលដ្ឋានច្បាប់សំរាប់ការគ្រប់គ្រងសំណល់រឹង ។ ដូច្នេះវាបានបង្កើតឡើងនូវក្របខ័ណ្ឌទាំងមូលដែលបញ្ហាគួរតែត្រូវបានដោះស្រាយទៅតាមលំនាំដូចខាងក្រោមនេះ ។<br>● ទោះបីក្រសួងបរិស្ថានបានចេញផ្សាយនូវសេចក្តីប្រកាសបន្ថែមលើអនុក្រឹត្យនេះ បទបញ្ញត្តិលំអិត ស្តង់ដា និងគោលការណ៍ណែនាំដែលគួរតែត្រូវបានបង្កើតដោយផ្អែកតាមនេះក៏ដោយ ក៏វានៅមិនទាន់មានការរៀបចំឱ្យបានល្អនៅឡើយដែរ ។<br>● អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង បានចែងថា សំណល់ត្រូវបានបែងចែកជាសំណល់ប្រកបដោយគ្រោះថ្នាក់ និងសំណល់គ្មានគ្រោះថ្នាក់ ប៉ុន្តែមិនបានធ្វើការកំណត់ ឬចាត់ថ្នាក់ប្រភេទសំណល់នោះឡើយ ។ ដូច្នេះជាក់ស្តែងវាមានការលំបាកក្នុងការញែកថាតើសំណល់ណាជាសំណល់ប្រកបដោយគ្រោះថ្នាក់ ហើយមួយណាមិនគ្រោះថ្នាក់ ។ ទោះបីជាចំណាត់ថ្នាក់នៃសំណល់ប្រកបដោយគ្រោះថ្នាក់ និងមិនគ្រោះថ្នាក់មានលក្ខណៈសមហេតុ សមផលទូលំទូលាយក៏ដោយ ក៏ចំណាត់ថ្នាក់លំអិតបន្ថែមទៀតគឺជាការចាំបាច់សំរាប់គ្រប់គ្រងសំណល់រឹង ជាពិសេសសំរាប់កំណត់អត្តសញ្ញាណរបស់អង្គ (ផលិតករ) ទទួលខុសត្រូវចំពោះការចាក់សំណល់រឹងទាំងនេះ ។<br>● អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង បានចែងថារដ្ឋអំណាចដែនដីទទួលខុសត្រូវលើការចាក់សំណល់ប្រកបដោយគ្រោះថ្នាក់ពីប្រភពបង្កើតក្នុងស្រុក ។ ប៉ុន្តែប្រភពក្នុងស្រុកនៅក្នុងអនុក្រឹត្យនេះ រួមមានគ្លីនិច និងមន្ទីរ ពេទ្យ ។ ការនេះចាំបាច់ត្រូវធ្វើការត្រួតពិនិត្យ ។<br>● ការប្រមូល ការដឹកជញ្ជូន និងការទុកដាក់សំណល់ប្រកបដោយគ្រោះថ្នាក់ពីរោងចក្រ តំរូវឱ្យមានការយល់ព្រមពីក្រសួងបរិស្ថាន ប៉ុន្តែការទទួលខុសត្រូវត្រួតត្រាចាត់ចែងមិនមានចែងឱ្យបានច្បាស់លាស់ឡើយ ។<br>● អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង បានចែងថា ក្រុងដែលជាអ្នកទទួលខុសត្រូវលើការគ្រប់គ្រងសំណល់គ្មានគ្រោះថ្នាក់ ត្រូវរៀបំផែនការគ្រប់គ្រងសំណល់ ។ ផែនការគ្រប់គ្រងសំណល់រឹងសំរាប់សាលាក្រុងដែលនឹងត្រូវបង្កើតនៅក្នុងការសិក្សានេះ គឺជាការធ្វើលើកទីមួយ ហើយដែលវិធីសាស្ត្ររៀបចំផែនការគ្រប់គ្រងសំណល់រឹង នេះត្រូវបានរំពឹងថា នឹងអាចយកទៅប្រើប្រាស់សំរាប់ទីក្រុងនានាទូទាំងប្រទេសនេះទៀត ។<br>● លក្ខន្តិកៈស្តីពីការគ្រប់គ្រងសំណល់រឹង និងគោលការណ៍ណែនាំលើការចាក់ និងបញ្ហាផ្សេងៗដើម្បីឱ្យមានការចូលរួម ពីសំណាក់ប្រជាជន គឺជាការចាំបាច់សំរាប់ក្រុងក្នុងការអនុវត្តការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ ។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ពុំឃើញមានលក្ខន្តិកៈ ឬគោលការណ៍ណែនាំទាំងនោះទេ ។<br>● ក្រសួងបរិស្ថានបានថ្លែងថាខ្លួនបានរកឃើញ ៩ ករណី ពីបទល្មើសចំពោះអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង និងសេចក្តីប្រកាសរបស់ក្រសួង និងការផាកពិន័យចំនួន ៤៤,២៣ លានរៀល ក្នុងឆ្នាំ ២០០២ អនុលោមទៅតាមច្បាប់ការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ ដែលបានចេញកាលពីខែមករា ឆ្នាំ ១៩៩៧ ។ ក្រុមសិក្សាបានគិតថា ករណីទាំងនេះគ្រាន់តែជាផ្នែកមួយនៃសកម្មភាពខុសច្បាប់ប៉ុណ្ណោះ ។ ឧទាហរណ៍ដូចជាបញ្ហាទឹកស្អុយ ។ មានកន្លែងចាក់ទឹកស្អុយមួយនៅទីលានចាក់សំរាមស្ទឹងមានជ័យ ។ ក្រុមហ៊ុនឯកជនប្រមូលទឹកស្អុយដែលមានរថយន្តប្រមូលចំនួន ១១គ្រឿង (រ.គ.ស.ភ មានតែ ៣គ្រឿង) មិនបានចាក់ទឹកស្អុយនៅទីនេះទេ ។ ភាគច្រើននៃទឹកស្អុយដែលបានប្រមូលដោយក្រុមហ៊ុនឯកជន គឺជាតួយ៉ាង នៃការចាក់ខុសច្បាប់ ។ | |

<table>
<tr><th>មុខបច្ចេកទេស</th><th>ខណ្ឌក្នុងក្រុង (ខណ្ឌទាំង ៤)</th><th>ខណ្ឌជាយក្រុង (ខណ្ឌទាំង ៣)</th></tr>
<tr><td>១២. រដ្ឋបាល និង ការរៀបចំ</td><td colspan="2">● នៅថ្នាក់ជាតិ វាច្បាស់ណាស់ដែលថាការគ្រប់គ្រងសំណល់រឹងត្រូវឋិតនៅក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន ។ ម៉្យាងវិញទៀត សាលាក្រុង ស.ក.ភ.ព ម.ប.ស្ល និង រ.គ.ស.ភ ត្រូវពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង និង ទំនាក់ទំនងរវាងស្ថាប័នទាំង ៣នេះ មានភាពមិនច្បាស់លាស់នៅឡើយ ។ ការគ្រប់គ្រងការចាក់សំណល់ និង សេវាសំអាត ក្នុងន័យជាក់ស្តែងត្រូវបានអនុវត្តដោយ រ.គ.ស.ភ ដែលចំណុះឱ្យ ស.ក.ភ.ព ។ លក្ខន្តិកៈរបស់ រ.គ.ស.ភ ត្រូវបានធ្វើឡើងដោយផ្អែកតាមស្ថានភាពជាក់ស្តែង ប៉ុន្តែនៅមិនទាន់បានទទួលការយល់ព្រមព្រៀង មក ដល់ខែកក្កដា ឆ្នាំ២០០៣ ពីសំណាក់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬក្រសួងបរិស្ថាន នៅឡើយ ទេ ។ ម៉្យាងវិញទៀត ប្រកាសលេខ ៨០ ដែលចេញដោយអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និង ក្រសួងបរិស្ថាន កាលពីខែកុម្ភៈ ឆ្នាំ ២០០៣ បានចែងថា ផែនការគ្រប់គ្រងសំណល់រឹង គួរតែត្រូវបានបង្កើត ឡើងដោយមន្ទីរបរិស្ថាន តាមក្រុងនិមួយៗ ។ យុត្តាធិការនៃការគ្រប់គ្រងសំណល់រឹងក្នុងក្រុងគួរតែមានឯកភាពរូបបនីយកម្មដោយ គ្មានការពន្យាពេល ។ ការ អនុម័តជាបន្ទាន់ទៅលើលក្ខន្តិកៈរបស់ រ.គ.ស.ភ រំពឹងថានឹងមានការបញ្ជាក់ដោយច្បាស់លាស់ពីយុត្តាធិការ នេះ ។<br>● ការងារប្រមូលសំណល់ និងសំអាតត្រូវបានផ្តល់កិច្ចសន្យាដល់ក្រុមហ៊ុនស៊ិនទ្រី តាមរយៈការទិញសិទ្ធិពីក្រុមហ៊ុន PSBK ក្នុងឆ្នាំ ២០០០ ។ កិច្ចសន្យានេះមានសុពលភាពសំរាប់រយៈពេល ៥០ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៧ ហើយ ដែលអនុញ្ញាតឱ្យក្រុមហ៊ុនស៊ិនទ្រី ធ្វើជំនួញជាអង្គភាពផ្តាច់មុខ និងធ្វើការប្រមូលថ្លៃសំរាមផងដែរ ។ ក្នុងករណី មានបញ្ហាកើតឡើង ដូចជាថាក្រុមហ៊ុននេះរំលោភលើកិច្ចសន្យា ពុំមានអង្គភាព ឬស្ថាប័នផ្នែកណាមានសិទ្ធិក្នុង ការផ្តល់សេវាជំនួសឱ្យស៊ិនទ្រី ឡើយ ។ ការបញ្ចៀសនូវឯកាធិភាព ឬភាពផ្តាច់មុខលើការប្រមូលសំរាម និង ការងារសំអាត គឺជាបញ្ហាសំខាន់ ។<br>● ស្របពេលដែលលក្ខនិកៈរបស់ រ.គ.ស.ភ មិនទាន់ទទួលបានការអនុម័តនៅឡើយ ស្ថានភាពបច្ចុប្បន្នរបស់វានៅ មានអស្ថេរភាពនៅឡើយដែរ ។ លើសពីនេះទៀត រ.គ.ស.ភ នៅមានភាពខ្សោយយោងទៅដល់ទ្រព្យធន (គ្រឿងចក្រ និងឧបករណ៍ផ្សេងៗ) ធនធានមនុស្ស (គុណភាព និងបរិមាណបុគ្គលិក) និងហិរញ្ញវត្ថុ ។ សាលាក្រុងបានធ្វើវិសោធនកម្មកិច្ចសន្យារវាងសាលាក្រុង និងក្រុមហ៊ុនស៊ិនទ្រី ហើយដែលបច្ចុប្បន្នអនុវត្តទៅលើ ការប្រមូលសំណល់ក្នុងតំបន់ NIP និងប្រតិបត្តិការណ៍នៅទីលានស្ទឹងមានជ័យ ។<br>● ការចាត់ចែងគ្រប់គ្រងការប្រមូលសំណល់ និងការងារសំអាតដែលកំពុងធ្វើដោយក្រុមហ៊ុនស៊ិនទ្រី និង រ.គ.ស.ភ ក្នុងក្រុងទាំងមូល គឺជាការងារលំបាក ។ ប្រព័ន្ធសំរាប់ការត្រួតពិនិត្យ និងអង្កេត លើការគ្រប់គ្រងសំណល់រឹង គួរតែបង្កើតឡើង ។</td></tr>
<tr><td>១៣. ដៃគូឯកជន និងសាធារណៈ</td><td colspan="2">ផ.យ.គ្រ.ស.រ ផ.ស[៤] បានចង្អុលបង្ហាញយ៉ាងច្បាស់ អំពីកិច្ចសន្យាសិទ្ធិផ្តាច់មុខរយៈពេល ៤៦ ឆ្នាំ លើការគ្រប់ គ្រងសំណល់រឹងជាមួយក្រុមហ៊ុនឯកជន មានបញ្ហាមួយចំនួនដូចខាងក្រោមនេះ ។<br>● ការដេញថ្លៃ និងការដាក់តម្លៃប្រកួតដោយតម្លាភាពលើសេវាដែលបានចុះកិច្ចសន្យាមិនត្រូវបានអនុវត្តឡើយ ។<br>● សកម្មភាពសេវា និងតម្លៃនៃការងាររបស់អ្នកម៉ៅការឯកជន មិនត្រូវបានប្រកួតប្រជែង និងអង្កេតដោយស្ថាប័ន ទទួលខុសត្រូវសាលាក្រុង ។<br>● អ្នកម៉ៅការមិនបានទទួលខុសត្រូវចំពោះអតិថិជន និងអ្នកជាវ លើស្តង់ដា និងបញ្ហាផ្សេងៗដែលខ្លួនបានធ្វើនោះ ឡើយ ។<br><br>បន្ថែមទៅលើបញ្ហាកិច្ចសន្យាដែលបានបញ្ជាក់ពីខាងលើ ប្រព័ន្ធត្រួតពិនិត្យ និងចាត់ចែងគ្រប់គ្រងរបស់សាលាក្រុង លើការគ្រប់គ្រងសំណល់រឹង នៅមានភាពខ្សោយ ដូចមានរៀបរាប់ខាងក្រោមនេះ ។<br>● ពុំមានទិន្នន័យគោលចាំបាច់សំរាប់គ្រប់គ្រងសំណល់រឹងទេ ដូចជាទិន្នន័យអត្រាប្រជាជនដែលមិនបានទទួលសេវា ប្រមូលសំរាម ទិន្នន័យស្តីពីគុណភាពសំណល់ចាក់ចោលតាមប្រភពបង្កើតនិមួយៗ តាមខ័ណ្ឌនិមួយៗ ឬតាម ក្រុមហ៊ុននិមួយៗ ។ ជាងនេះទៀត ប្រព័ន្ធប្រមូលទិន្នន័យក៏មិនត្រូវបានបង្កើតដែរ ។</td></tr>
</table>

| មុខបច្ចេកទេស | | ខណ្ឌក្នុងក្រុង (ខណ្ឌទាំង ៤) | ខណ្ឌជាយក្រុង (ខណ្ឌទាំង ៣) |
|---|---|---|---|
| | | ● ដោយសារកង្វះខាតទិន្នន័យគោល ឯកតាតម្លៃនៃផ្នែកបន្ទាប់បន្សំនិមួយៗលើការគ្រប់គ្រងសំណល់រឹង (ដូចជាការប្រមូលសំណល់ ការប្រមូលទឹកស្អុយ ការចាក់ចុងក្រោយ) មិនត្រូវបានដឹងឡើយ ។<br>● សាលាក្រុង មិនបានត្រួតពិនិត្យ ឬចាត់ចែងគ្រប់គ្រងប្រតិបត្តិការណ៍ការងាររបស់ក្រុមហ៊ុនឯកជនលើការគ្រប់គ្រងសំណល់រឹង ហើយក៏ពុំមានផ្នែកណាដែលត្រូវធ្វើការងារនេះដែរ ។ ហើយក៏មានការខ្វះខាតលើមុខងារក្នុងការទទួលការប្តឹងមិនពេញចិត្តពីសំណាក់ប្រជាជនដែរ ។<br>ដូចបង្ហាញពីខាងលើ ការចងក្រងទិន្នន័យគោលលើការគ្រប់គ្រងសំណល់រឹង និងការបង្កើតនូវកំរងទិន្នន័យមូលដ្ឋានគឺជាការចាំបាច់បន្ទាន់ ។ | |
| | ១៤. ការកសាងសមត្ថភាព | ● យោងតាម ផ.យ.គ្រ.ស.រ ផ.ស កម្មវិធីខ្លះៗត្រូវបានធ្វើដោយធនាគារអភិវឌ្ឍន៍អាស៊ី និងណូរ៉ាដ សំរាប់រយៈពេល ៥ឆ្នាំ ដើម្បីពង្រឹង ស.ក.ភ.ព និង រ.គ.ស.ភ ។ ទោះបីជាស្ថាប័នទាំងនេះនៅមានភាពខ្សោយ ការអភិវឌ្ឍន៍រចនាសម្ព័ន្ធដែលមានស្រាប់បច្ចុប្បន្នរបស់ខ្លួន ត្រូវការឱ្យមានការជួយជ្រោមជ្រែងយ៉ាងច្រើន ។<br>● ទោះបីជារចនាសម្ព័ន្ធរបស់ រ.គ.ស.ភ ត្រូវខានអភិវឌ្ឍន៍ក៏ដោយ ក៏សេវារបស់រដ្ឋាករនេះគ្របដណ្តប់តែត្រឹម ២,១% នៃចំនួនប្រជាជនក្នុងក្រុង និងហាក់ដូចជាពុំឃើញមានប្រតិបត្តិការណ៍អ្វីសោះនៅឯទីលានស្ទឹងមានជ័យ ប៉ុន្តែគឺទីលានចាក់ចំហរដដែល ។ ទោះបីជាលក្ខនិកៈរបស់ រ.គ.ស.ភ បានចែងថា ការអង្កេតលើសំណល់រឹង និងសំណល់រាវ របស់ក្រុមហ៊ុនអាជីវកម្មឯកជន គឺជាកិច្ចការមួយរបស់ រ.គ.ស.ភ ក៏ដោយ ក៏ រ.គ.ស.ភ មិន បានចាត់ចែងគ្រប់គ្រង<br>ឬត្រួតពិនិត្យការងារគ្រប់គ្រងសំណល់រឹងក្នុងទីក្រុងដែលធ្វើដោយក្រុមហ៊ុនឯកជនឡើយ។<br>● ជាសន្និដ្ឋាន ការអភិវឌ្ឍន៍ធនធានមនុស្សរបស់ រ.គ.ស.ភ បន្តទៀតមានសារៈសំខាន់ណាស់ដើម្បីឱ្យ រ.គ.ស.ភ អាចប្រតិបត្តិការណ៍ និងត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងសំណល់រឹងសំរាប់ក្រុងភ្នំពេញដោយចីរភាព និងខានត្រឹមត្រូវ។ ការទទួលបានចំណេះដឹងលើផ្នែកប្រមូលសំរាម និងសេវាសំអាត និងប្រតិបត្តិការណ៍នៅទីលាន គឺជាការសំខាន់សំរាប់វត្តមានរបស់អង្គភាព ។ ការទទួលបានចំណេះដឹងនេះអាចជួយផ្តល់ដល់ រ.គ.ស.ភ ឬអង្គភាពផ្សេងទៀតនៅក្នុងការទទួលខុសត្រូវរបស់សាលាក្រុងសំរាប់ចំណេះដឹងលើការគ្រប់គ្រងសំណល់រឹង និងត្រួតពិនិត្យការងារ នេះឱ្យខានត្រឹមត្រូវ ដែលជាការទទួលខុសត្រូវចំបងរបស់ក្រុមហ៊ុនឯកជន ។ ហេតុនេះដើម្បីអភិវឌ្ឍន៍ធនធាន មនុស្សរបស់ រ.គ.ស.ភ ហើយចំណុចអាទិភាពគួរតែដាក់ជូនលើការទទួលបាននូវចំណេះដឹងស្តីពីការប្រតិបត្តិការណ៍លើការគ្រប់គ្រងសំណល់រឹង ។<br>● ម៉្យាងវិញទៀត សេវាប្រមូល ត្រួតពិនិត្យ អង្កេត និងប្រតិបត្តិការណ៍ទីលានគួរតែជាការទទួលខុសត្រូវរបស់អង្គភាពដាច់ពីគ្នា ពីអង្គភាពប្រតិបត្តិ តួយ៉ាងដូចជា រ.គ.ស.ភ ។ វាមានសារៈសំខាន់ចាំបាច់សំរាប់សាលាក្រុង ក្នុងការបង្កើតសកម្មភាពខាងលើនេះឱ្យខានឆាប់រហ័សតាមដែលអាចធ្វើបាន ។ | |
| | ១៥.ស្ថានភាពហិរញ្ញវត្ថុ | ● មូលដ្ឋានហិរញ្ញវត្ថុរបស់ រ.គ.ស.ភ មានភាពខ្សោយ ជាក់ស្តែងគឺមានដល់ ៧០% នៃចំណូលដែលអាស្រ័យលើតម្លៃចាក់សំណល់ដែលបង់ដោយក្រុមហ៊ុនស៊ិនទ្រី ។ ចំណូលសរុបក្នុងឆ្នាំ ២០០២ មាន ១៥៩.០០០ ដុល្លា និងពុំមានហិរញ្ញវត្ថុគាំទ្របន្ថែមពីសាលាក្រុងចំពោះ រ.គ.ស.ភ ឡើយ ។ ការសងលើប្រាក់កម្ចី និងការប្រាក់ ក្នុងឆ្នាំ ២០០២ មានប្រហែល ២២.០០០ ដុល្លាសហរដ្ឋ ។ សមតុល្យចំណូល និងចំណាយប្រចាំឆ្នាំពុំមានបញ្ហា ទេ ប៉ុន្តែរដ្ឋាករនេះពុំមានថវិការសំរាប់ទិញគ្រឿងចក្រ និងរថយន្តថ្មីៗ ឬដើម្បីធ្វើការកែលំអទីលានចុងក្រោយ ទេ ។ សូម្បីតែថវិកាសំរាប់ប្រតិបត្តិការណ៍ និងថែទាំទ្រព្យធនដែលមានស្រាប់ក៏មានលក្ខណៈយ៉ាប់យ៉ឺនដែរ ។<br>● ស្ថានភាពហិរញ្ញវត្ថុរបស់សាលាក្រុងក៏មានសភាពធ្ងន់ធ្ងរដែរ ។ ចំណូលសរុបប្រចាំឆ្នាំ ២០០២ មាន ២៦,៦៣ពាន់លានរៀល (ប្រហែល ៦,៩៤ លានដុល្លាសហរដ្ឋ) ដែលមានការតានតឹងក្នុងការឧបត្ថម្ភធនលើការងារគ្រប់គ្រងសំណល់រឹងរបស់ រ.គ.ស.ភ ។<br>● តំបន់ដែល រ.គ.ស.ភ ផ្តល់សេវាប្រមូលសំរាម នៅមានកំណត់ ។ មកទល់ឆ្នាំ ២០០៣ សេវាប្រមូលរបស់ក្រុមហ៊ុនស៊ិនទ្រី មាន ១៣០.០០០ ផ្ទះ និងស្ថាប័ន ហើយដែល រ.គ.ស.ភ មានតែ ៣.៤០០ (២,១%) ។ ជាងនេះទៀត តំបន់ផ្តល់សេវារបស់ រ.គ.ស.ភ ភាគច្រើនជាតំបន់លំនៅដ្ឋាន ហើយដែលថ្លៃប្រមូលសំរាម សំរាប់ជាង ៣.២០០ ផ្ទះ មានតែ ១ដុល្លា/ខែ ប៉ុណ្ណោះ ។ ទោះបីជា រ.គ.ស.ភ ប្រមូលថ្លៃនេះពីអ្នកទទួល | |

| មុខបច្ចេកទេស | ខ័ណ្ឌក្នុងក្រុង (ខ័ណ្ឌទាំង ៤) | ខ័ណ្ឌជាយក្រុង (ខ័ណ្ឌទាំង ៣) |
|---|---|---|
| | ផលក្នុងតំបន់នេះទាំងអស់គ្នាក៏ដោយ ក៏ប្រាក់ចំណូលបានត្រឹមតែ ៤.៣០០ ដុល្លា សហរដ្ឋក្នុងមួយខែដែរ ។ ការប្រមូលថ្លៃសំរាមជាមធ្យមក្នុងមួយខែ ក្នុងឆ្នាំ ២០០២ មានប្រហែលជា ២.៥៦០ ដុល្លា ដូច្នេះអត្រានៃការប្រមូលថ្លៃនេះ មាន ៦០% នៅក្នុងតំបន់ NIP ។ យោងតាមនេះ មិនត្រឹមតែការទិញរថយន្តថ្មីៗនោះទេ សូម្បីតែថវិកាសំរាប់ការងារថែទាំរបស់ខ្លួន ក៏ជួបការលំបាកដែរ ។<br>● រចនាសម្ព័ន្ធពន្ធបច្ចុប្បន្នសំរាប់គ្រប់គ្រងសំណល់ក្រុង ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាង រ.គ.ស.ភ ស៊ិនទ្រី និងសាលាក្រុងភ្នំពេញ ។ កិច្ចព្រមព្រៀងនេះគួរតែពិនិត្យសារឡើងវិញដើម្បីរៀបចំទៅលើការចំណាយបន្ថែម ប្រសិនបើមានការអភិវឌ្ឍន៍ លើទីលានចាក់សំរាមថ្មី និងដើម្បីជួយជំរុញដល់ប្រព័ន្ធសេវាគ្រប់គ្រងសំណល់រឹងរបស់ រ.គ.ស.ភ ដើម្បីអាច អនុវត្តទៅបានដោយប្រសិទ្ធិភាព ។<br>● រចនាសម្ព័ន្ធពន្ធត្រូវតែមានការសំរបសំរួលចាប់តាំងពីទស្សនៈលើសមភាព ។ សំណល់តាមផ្ទះ និងតាមស្ថាប័ន ត្រូវបានធ្វើចំណាត់ប្រភេទយ៉ាងទូលំទូលាយ អាស្រ័យទៅនឹង បរិមាណ និង ឬប្រភេទសំណល់ ហើយនិងតម្លៃដែលត្រូវដាក់សំរាប់ចំណាត់ប្រភេទនិមួយៗ ។ ដើម្បីឱ្យមានភាពកាន់តែច្បាស់លាស់ទៅតាម "ផលប្រយោជន៍នៃការបង់ថ្លៃ" គោលការណ៍ ការធ្វើចំណាត់ប្រភេទឱ្យបានហ្មត់ចត់ គួរតែត្រូវបានពិចារណា ។<br>● បច្ចុប្បន្នក្រុមហ៊ុនស៊ិនទ្រី បានគិតប្រាក់ថ្លៃសំរាម ចូលទៅក្នុងវិក័យប័ត្រថ្លៃភ្លើងអគ្គិសនី ។ ប៉ុន្តែក្រុមហ៊ុនស៊ិនទ្រី បានបង្កើតថ្លៃនេះដោយផ្អែកតាមការសិក្សាផ្ទាល់របស់ខ្លួន ហើយបញ្ជូនវិក័យប័ត្រនេះទៅឱ្យអតិថិជនដោយមិន មានការព្រមព្រៀងពីពួកគាត់ឡើយ ដែលជាហេតុធ្វើឱ្យមានការប្តឹងផ្តល់មិនពេញចិត្ត និងមិនបង់ថ្លៃវិក័យប័ត្រជា ច្រើនទៀតផង ។ ដើម្បីកែលំអលើអត្រានៃការប្រមូលថ្លៃនេះ តម្លៃសេវាប្រមូលសំរាមគួរតែគិតដោយផ្អែកលើ កិច្ចព្រមព្រៀងរវាងក្រុមហ៊ុនស៊ិនទ្រី និងអតិថិជន ។<br>● ក្រុងភ្នំពេញចែកចេញជា ៧ខ័ណ្ឌ ហើយដែលមាន ៧៦សង្កាត់ ដែលចាត់ថាជាផ្នែកតូចជាងគេក្នុងរចនាសម្ព័ន្ធរដ្ឋបាល ។ ប្រសិទ្ធិភាពនៃប្រព័ន្ធប្រមូលថ្លៃសំរាមនេះ អាចនឹងធ្វើដោយមានកិច្ចសហការជាមួយសង្កាត់ ដែលគេជឿថាអាចនឹងមានភាពប្រសើរឡើង ។<br>● តម្លៃចាក់ចោលរបស់ស៊ិនទ្រីបច្ចុប្បន្នមានប្រហែលជា ០,៥ ដុល្លាក្នុងមួយតោនសំរាម ហើយនៅពេលដែលទីលានថ្មីត្រូវបានសាងសង់រួច វានឹងត្រូវបង់ ០,៧៥ ដុល្លាក្នុងមួយតោនសំរាម ។ ប៉ុន្តែក្នុងលក្ខណៈជាទីលានបច្ចេកទេស តម្លៃប្រតិបត្តិការណ៍ទឹមនេះមិនអាចដំណើរការទីលានទៅបានទេ ដូច្នេះចាំបាច់ត្រូវធ្វើការពិនិត្យនូវតម្លៃចាក់នេះសារឡើងវិញ ។ | |
| | ● យោងទៅតាមស្ថានភាពធ្ងន់ធ្ងររបស់សាលាក្រុង និង រ.គ.ស.ភ ជាក់ស្តែងការផ្គត់ផ្គង់ហិរញ្ញប្បទានដោយខ្លួនឯងសំរាប់ធ្វើការអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មី គឺមិនអាចមានលទ្ធភាពទៅរួចនោះឡើយ ។ ដោយយោងទៅដល់ការផ្តល់សេវាសាធារណៈ ប្រទេស ឬទីក្រុងនេះ គួរតែទទួលខុសត្រូវលើការបែងចែកថវិកាឱ្យបានច្រើនតាមដែលអាចធ្វើទៅបានទៅលើផ្នែកនេះ ប៉ុន្តែជំនួយថវិកាមកពីប្រទេសជាម្ចាស់ជំនួយ ឬស្ថាប័នអន្តរជាតិ គឺមិនអាចជៀសរួចឡើយសំរាប់រៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹងដ៏ត្រឹមត្រូវនេះ ដោយសារតែកង្វះខាតហិរញ្ញវត្ថុរបស់ប្រទេស ឬ ក្រុងភ្នំពេញនេះ ។ | |
| **១៦. អប់រំសាធាណៈ និងកិច្ចសហការ** | ● និរន្តរភាពនៃការគ្រប់គ្រងសំណល់រឹងមិនអាចទទួលបានឡើយបើគ្មានការយល់ដឹងឱ្យបានគ្រប់គ្រាន់ និងគ្មានកិច្ចសហការពីប្រជាជន ។ អាជ្ញាធរគ្រប់គ្រងសំណល់រឹងនៅតាមបណ្តាប្រទេសអភិវឌ្ឍន៍បានព្យាយាមបង្កើនចំណេះដឹងសាធារណៈ និងស្វែងរកការគាំទ្រសហការពីសំណាក់ប្រជាជនតាមមធ្យោបាយជាច្រើន ។ សកម្មភាពទំនាក់ទំនងសាធារណៈនេះ គឺឃើញមានការលំបាកនៅក្នុងក្រុងភ្នំពេញ ។<br>● តាមរបាយការណ៍ឱ្យដឹងថា ក្រុមហ៊ុនស៊ិនទ្រី ជាក្រុមហ៊ុនផ្តាច់មុខលើការផ្តល់សេវាប្រមូលសំណល់ និងសំអាតក្នុងក្រុងភ្នំពេញ ប្រើប្រាស់ទឹកប្រាក់ចំនួន ១០០.០០០ដុល្លាសហរដ្ឋ សំរាប់ធ្វើសកម្មភាព PR ។ ប៉ុន្តែមិនបានទទួលការសហការឱ្យបានគ្រប់គ្រាន់ពីសំណាក់ប្រជាជនសំរាប់ការចាក់សំណល់ឱ្យបានត្រឹមត្រូវឡើយ ។<br>● ដើម្បីកាត់បន្ថយនូវការពង្រាយសំណល់ និងបង្កើនប្រសិទ្ធិភាពក្នុងការប្រមូល ចាំបាច់ត្រូវបង្កើតបទបញ្ញត្តិលើការចាក់ និងលើកស្ទួយយុទ្ធនាការអប់រំសាធារណៈក្នុងន័យផ្សព្វផ្សាយបទបញ្ញត្តិទាំងនេះតាមរយៈការប្រឹងប្រែងចូលរួមរបស់សាលាក្រុង និងសាធារណៈជន ។ | |

<table>
<tr><th colspan="2">មុខបច្ចេកទេស</th><th>ខ័ណ្ឌក្នុងក្រុង (ខ័ណ្ឌទាំង ៤)</th><th>ខ័ណ្ឌជាយក្រុង (ខ័ណ្ឌទាំង ៣)</th></tr>
<tr><td></td><td></td><td colspan="2">• យោងតាមលទ្ធផលលើការស្ទង់មតិសាធារណៈ: ការយល់ដឹងរបស់ប្រជាជនលើការគ្រប់គ្រងសំណល់រឹងនៅមិនទាន់បានជ្រៅជ្រះនៅឡើយទេ ។ ប្រជាជនជាច្រើនបារម្ភចំពោះបញ្ហាពង្រាយសំរាមដែលធ្វើឱ្យខាត់បង់ដល់សោភ័ណភាពទីក្រុង ប៉ុន្តែពួកគាត់មិនបានដឹងច្រើនអំពីតួនាទីសំខាន់ដែលពួកគាត់ត្រូវធ្វើចំពោះការកាត់បន្ថយបរិមាណសំរាម និងការកែច្នៃសំណល់ឡើយ ។<br>• ដើម្បីរក្សាទីក្រុងឱ្យមានសោភ័ណភាពស្អាតល្អ និងដើម្បីអភិរក្សបរិស្ថានអនាម័យ ការចូលរួមសហការពីសំណាក់ប្រជាជនគឺជារឿងជៀសមិនផុតឡើយ ។ អាជ្ញាធរត្រូវតែធ្វើសកម្មភាព PR ឱ្យខានសកម្ម ។</td></tr>
<tr><td></td><td>១៧. ការគ្រប់គ្រងសំណល់គ្រោះថ្នាក់</td><td colspan="2">• អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹងខានកំណត់នូវបញ្ញត្តិជាមូលដ្ឋានសំរាប់គ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ រួមទាំងសំណល់ឆ្លងផងដែរ ប៉ុន្តែស្តង់ដា និងគោលការណ៍ណែនាំមិនទាន់បានអភិវឌ្ឍន៍នៅឡើយ ទោះបីជាជាក់ស្តែងវាត្រូវការសំរាប់ការងារត្រួតពិនិត្យ និងធ្វើនិយ័តកម្មការគ្រប់គ្រងសំណល់នេះក៏ដោយ ។<br>• ទីលានឯកជនសំរាប់ចាក់សំណល់ប្រកបដោយគ្រោះថ្នាក់ត្រូវបានអនុម័តយល់ព្រមដោយក្រសួងបរិស្ថាន និងត្រូវ បានសាងសង់ក្នុងស្រុកអង្គស្នួលដោយក្រុមហ៊ុនអាជីវកម្ម សារ៉ាំ ប៉ុន្តែការត្រួតពិនិត្យមិនមានគ្រប់គ្រាន់ឡើយ ។ មន្ទីរពេទ្យសំខាន់ៗមួយចំនួនមានឡសំរាប់រំលាយសំណល់វេជ្ជសាស្ត្រ ប៉ុន្តែភាគច្រើនមិនបានដំណើរការល្អទេ ដោយសារបញ្ហាហិរញ្ញវត្ថុ និងបច្ចេកទេស ។<br>• ក្រសួងឧស្សាហកម្មបានចេញប្រកាសសំរាប់ធ្វើការអង្កេត ដែលតំរូវឱ្យរោងចក្រធ្វើរបាយការណ៍ស្តីពីការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន និងធ្វើការណែនាំឱ្យពួកគាត់ធ្វើប្រព្រឹត្តិកម្ម និងចាក់សំណល់ទាំងនោះឱ្យខានត្រឹមត្រូវ ប៉ុន្តែការអនុវត្តន៍ប្រកាសនេះនៅមានភាពខ្សោយ ។<br>• ក្រុមសិក្សាខានសិក្សាលើការគ្រប់គ្រងសំណល់រឹងនៅតាមបណ្តាស្ថាប័នវេជ្ជសាស្ត្រចំនួន ៤១កន្លែង និងបានរកឃើញថា រាល់ស្ថាប័នទាំងនោះបានដឹងថាប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ ត្រូវបានធ្វើនិយ័តកម្មដោយច្បាប់ ។<br>• បុគ្គលិកធ្វើការនៅតាមស្ថាប័នវេជ្ជសាស្ត្របានយល់ដឹងអំពីប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ និងហានិភ័យដែលបណ្តាលមកពីសំណល់ប្រកបដោយគ្រោះថ្នាក់ ឬសំណល់ឆ្លង ។ ស្ថាប័នវេជ្ជសាស្ត្រភាគច្រើនបានចាត់វិធានការទប់ស្កាត់ប្រឆាំងនឹងការឆ្លងនេះ និងបានប្រមូលញែកសំណល់ទាំងនេះទុក នៅក្នុងបរិវេណរបស់ខ្លួន ។<br>• បរិមាណនៃការញែកចំណាត់ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ឬឆ្លង នៅមានកំរិតទាប ។<br>• ស្ថាប័នវេជ្ជសាស្ត្រជាច្រើនមិនបានរាយការណ៍អំពីសំណល់ប្រកបដោយគ្រោះថ្នាក់ទេ ។ ទាំងនេះបង្ហាញនូវកង្វះខាតស្មារតីភ្ញាក់រលឹកលើអត្ថន័យ លក្ខណៈ និងការកំណត់អំពីសំណល់ប្រកបដោយគ្រោះថ្នាក់ ។<br>• ស្ថាប័នវេជ្ជសាស្ត្រជាច្រើនបានឆ្លើយថា លក្ខណៈនៃការចាក់សំណល់ឆ្លងដែលបានប្រមូល ឬសំណល់ប្រកបដោយគ្រោះថ្នាក់ មិនទាន់ជាទីពេញចិត្តទេ ។ សំណល់ឆ្លង ឬសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវបានញែកចេញពីសំណល់ក្រុងទូទៅ នៅពេលប្រមូល ហើយត្រូវបានរំលាយក្នុងឡ ឬត្រូវបានប្រគល់ជូនទៅឱ្យអ្នកម៉ៅការឯកជនដើម្បីធ្វើប្រព្រឹត្តិកម្ម ។ មានអ្នកខ្លះខានប្រាប់ថា អ្នកម៉ៅការបានលាយសំណល់ឆ្លង ឬសំណល់ប្រកបដោយគ្រោះថ្នាក់ជាមួយនឹងសំណល់ក្រុងទូទៅក្នុងពេលប្រមូល រួចយកទៅចាក់រួមគ្នានៅទីលានចុងក្រោយតែម្តង ។ ស្របពេលដែលគ្មានវិធាការធ្វើប្រព្រឹត្តិកម្មសំណល់ឆ្លង ឬសំណល់ប្រកបដោយគ្រោះថ្នាក់នៅឯទីលានទេ សុខភាពប្រជាជន និងបរិស្ថានក៏ត្រូវបានរងការគំរាមកំហែង ។<br>• ស្ថាប័នវេជ្ជសាស្ត្របានថ្លែងថា គាត់បានត្រៀមរួចជាស្រេចនូវការសហការជាមួយរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានលើប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រឱ្យខានត្រឹមត្រូវ ។ ប៉ុន្តែពួកគាត់ភាគច្រើន ក៏បានឆ្លើយថាពួកគាត់ត្រូវការឱ្យមានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីរដ្ឋាភិខាល<br>ដើម្បីប្រែក្លាយប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រឱ្យ ខានត្រឹមត្រូវនេះឱ្យទៅជាសកម្មភាពជាក់ស្តែង ។</td></tr>
</table>

### 2.3.3 បញ្ហាបច្ចុប្បន្នពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង

បញ្ហាខាងក្រោមនេះត្រូវបានសង្ខេបដោយផ្អែកទៅតាមស្ថានភាពនៃការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្នក្នុងភ្នំពេញ ។

#### a. ការពង្រីកសេវាប្រមូលសំរាម

សាលាក្រុងភ្នំពេញបានផ្តល់កិច្ចសន្យាលើការគ្រប់គ្រងសំណល់រឹងក្រុងដល់ក្រុមហ៊ុនឯកជនផ្អែកតាមកិច្ចព្រមព្រៀងផ្តល់សិទ្ធិផ្តាច់មុខ ។ ប៉ុន្តែដោយសារថាសេវាប្រមូលរបស់ក្រុមហ៊ុនឯកជនមានកំរិតតែចំពោះតំបន់ដែលអាចផ្តលផល់ចំណេញបាននោះ ទើបតំបន់ដែលពុំបានទទួលសេវានេះមានច្រើនគួរសមដែរ ។ តំបន់ទាំងនេះភាគច្រើនជាតំបន់សំណង់អនាធិបតេយ្យដែលជាលំនៅដ្ឋានសំរាប់អ្នកក្រក្នុងទីក្រុងហើយដែលពិបាកក្នុងការចេញចូល ដោយសារតែមានផ្លូវតូចចង្អៀត ។ ហើយតំបន់ទាំងនេះថិតនៅជុំវិញទីក្រុងដែលមានដង់ស៊ីតេទាប និងសេវាប្រមូលសំរាមមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាពឡើយ ។

ចេញពីចំណុចអភិរក្សបរិស្ថានទីប្រជុំជន តំបន់ដែលគ្មានសេវាប្រមូល និងតំបន់ដែលមានសេវាតិចតួចមិនគ្រប់គ្រាន់ចាំបាច់ត្រូវតែលប់បំបាត់ចោល ។ រាល់អ្នករស់នៅក្នុងក្រុងទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការទទួលបាននូវសេវាសាធារណៈហើយ ដែលសាលាក្រុងមានកាតព្វកិច្ចក្នុងការធានាចំពោះការផ្តល់សេវាទាំងនេះ ។

#### b. ការជៀសវាងប្រព័ន្ធអាស្រ័យស្ថាប័នឯកជន

ក៏ដូចជាអគ្គិសនី និងទឹកដែរ ការប្រមូលសំណល់គឺជាសេវាសាធារណៈមួយដែលមានសារៈសំខាន់ដល់ជីវិតក្នុងក្រុង ។ ដូច្នេះការបញ្ឈប់បណ្តោះអាសន្ននៃសេវានេះអាចបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំង អាចថាជាការបញ្ឈប់មុខងាររបស់ទីក្រុង ។ ស្របពេលដែលសេវាប្រមូលសំរាមក្នុងភ្នំពេញបច្ចុប្បន្នធ្វើឡើងដោយក្រុមហ៊ុនឯកជនផ្តាច់មុខ ទីក្រុងនេះអាចនឹងជួបនូវស្ថានភាពវិបត្តិដូចជាថាអាចមានបញ្ហាកើតឡើងដោយយថាហេតុ តួយ៉ាងក្រុមហ៊ុនឯកជនត្រូវក្ស័យធន ។ សាលាក្រុងភ្នំពេញត្រូវចាត់វិធានការដើម្បីបញ្ចៀសនូវប្រព័ន្ធនេះដែលអាស្រ័យតែទៅលើស្ថាប័នឯកជន ។

#### c. ការធានាដល់ទីលានថ្មីចាក់ចុងក្រោយ

ក្រុមសិក្សាខានធ្វើការប៉ាន់ស្មានទីលានចាក់សំរាមស្ទឹងមានជ័យដែលជាទីលានតែមួយគត់ ដែលអាចផ្ទុកសំរាមបានតិចជាងតែ ២ឆ្នាំ ទៀតប៉ុណ្ណោះ ។ ហេតុនេះការអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីគឺជាករណីចាំបាច់ និងបន្ទាន់ ។

#### d. ការពង្រីកអាយុកាលរបស់ទីលានដែលមានស្រាប់

ដូចមាននៅក្នុងការរៀបចំផែនការ ការរៀបចំគំរោង និងការសាងសង់ទីលានថ្មីត្រូវការពេលវេលា ៣-៤ឆ្នាំ ឯអាយុកាលនៃការផ្តល់សេវារបស់ទីលានស្ទឹងមានជ័យ មានមិនគ្រប់គ្រាន់ទេ (តិចជាង ២ឆ្នាំទៀតប៉ុណ្ណោះ) ។ ដូច្នេះវិធានការបន្ទាន់មួយត្រូវតែយកមកអនុវត្តឱ្យខានរហ័សតាមដែលអាចធ្វើបាន ដើម្បីពន្យាអាយុកាលរបស់ទីលានដែលមានស្រាប់នេះ ។ ក្នុងខណៈដែលទីលានស្ទឹងមានជ័យនេះជាទីលានចាក់ចំហរ បរិស្ថាននៅទីនោះមានសភាពលំបាក ដូចជាខ្លិនអាក្រក់ ផ្សែងបណ្តាលមកពីភ្លើងឆេះទីលាន និងការរាយប៉ាយនៃសំរាម គឺជាបញ្ហារាល់ថ្ងៃ ។ ដើម្បីទទួល បានការយល់ដឹងពីអ្នកស្រុកដែលនៅទីនោះ យោងតាមការអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីវាជាការងារបន្ទាន់ដែលត្រូវកែ លំអបរិស្ថានទីនេះឱ្យខានប្រសើរ ។

#### e. ការលើកស្ទួយដល់គោលការណ៍ 3Rs

កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃ（3Rs）គឺជាគោលការណ៍គ្រឹះនៃការគ្រប់គ្រងសំណល់រឹងដែលត្រូវបានយកមកអនុវត្តនៅពាសពេញពិភពលោក ។ ដូចបានបញ្ជាក់ពីខាងលើមកហើយ សមត្ថភាពផ្ទុករបស់ទីលានក្នុងក្រុងភ្នំពេញមានមិនគ្រប់គ្រាន់ទេ ហើយការធានាដល់ការបង្កើតទីលានចាក់សំរាមថ្មីគឺជាបញ្ហាធ្ងន់ធ្ងរបន្ទាន់ ។ ទោះជាមានទំហំតិចតួចក៏ដោយដើម្បីពង្រីកអាយុកាលចាក់របស់ទីលានដែលមានស្រាប់ ការកាត់បន្ថយបរិមាណបង្កើតសំណល់គឺជាកត្តាសំខាន់ នៅក្រោមស្ថានភាពហិរញ្ញវត្ថុដ៏តានតឹងដូច្នេះ ។ ជាងនេះទៀត ការសិក្សាបានបង្ហាញថា ៧០% នៃសំណល់ក្នុងក្រុងជាសំណល់ដែលអាចធ្វើជីកំប៉ុស្តបាន ដូចជាសំណល់តាមផ្ទះ តាមសួនច្បារក្នុងផ្ទះ និង ២៤% ទៀត ជាសំណល់អាចកែច្នៃ បានដូចជា ក្រដាស ប្លាស្ទិច លោហៈ និងដប ។ ហេតុនេះវាជាការចាំបាច់ណាស់ក្នុងការកាត់បន្ថយបរិមាណសំណល់តាម រយៈការលើកស្ទួយដល់សកម្មភាពកែច្នៃអោយបានសកម្មខ្លាំងក្លាឡើង ។